01070856

**Declassified to Public**
**05 May 2021**

លេខ/No: D239

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 03 / 03 / 2015
ម៉ោង (Time/Heure): 15:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

| | |
|---|---|
| **សំណុំរឿងលេខ៖** | **០០៤/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស** |
| ចំពោះមុខ ៖ | **សហចៅក្រមស៊ើបអង្កេត** |
| កាលបរិច្ឆេទ ៖ | **ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥** |
| ភាសា ៖ | **ខ្មែរ/អង់គ្លេស [អង់គ្លេស ភាសាដើម]** |
| ចំណាត់ថ្នាក់ឯកសារ ៖ | **សម្ងាត់** |

# ដីកាសម្រេចដាក់អ៊ឹម ចែម ឲ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីរបស់អ៊ឹម ចែម**
John R. W. D. Jones
ប៊ិត ស៊ាងលឹម

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រីនណា
វ៉ែន ពៅ

Laure DESFORGES
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Emmanuel JACOMY
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

**បានឃើញ** ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២00៤ ("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក")។

**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញា ដាក់នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២00៩ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ")[1]។

**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ដាក់នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២0១១("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមឆ្នាំ ២0១១")[2]។

**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាយេនឌ័រ ដែលបានដាក់នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២0១៤ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមឆ្នាំ ២0១៤")[3]។

**បានឃើញ** ការបើកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់អំពីការរំលោភបំពានក្រមព្រហ្មទណ្ឌ **ឆ្នាំ ១៩៥៦ អនុសញ្ញាស្តីពីការទប់ស្កាត់ និងផ្តន្ទាទោសចំពោះអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ អនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣(ថ្មី), ៤, ៥,៦, ២៩ និង៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ព្រមទាំងមាត្រា ២0៩, ២១0, ៥00, ៥0១, ៥0៣, ៥0៤, ៥0៥, ៥0៦, ៥0៧, និង ៥0៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦។

**បានឃើញ** មាត្រា ២៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា ២៥ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង អ.វ.ត.ក")។

---

[1]សំណុំរឿង00៤ ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញា* ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ") ថ្ងៃទី ២0 ខែ វិច្ឆិកា ឆ្នាំ ២00៨។ សំណុំរឿង00៤ ឯកសារD1/1*ការជូនដំណឹងអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី* ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២00៩។

[2] សំណុំរឿង 00៤ ឯកសារ D65 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់ ១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម* ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២0១១។

[3]សំណុំរឿង 00៤ ឯកសារ D191 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាយេនឌ័រ* ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២0១៤។

**បានឃើញ**វិធាន ២, ១៥, ២១, ៤៥, ៥៥, ៦២, ៧២ និង៨១ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ("វិធានផ្ទៃក្នុង")។

**បានឃើញ**ករណីខ្វែងយោបល់គ្នាចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៣ និងថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤។

**ប្រវត្តិនីតិវិធី**

១. នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលក្នុងនោះ គាត់បានចោទថា អ៊ឹម ចែម ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក។ ការចោទប្រកាន់បន្ថែមទៀតក៏បានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមឆ្នាំ ២០១១ ដាក់នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមឆ្នាំ ២០១៤ ដាក់នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤។

២. នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង("ស.ច.ស.អ.ប") បានជូនដំណឹង អ៊ឹម ចែម ថា គាត់ជាប់ឈ្មោះជាជនសង្ស័យម្នាក់នៅក្នុងការស៊ើបអង្កេតដែលកំពុងបន្តដំណើរការនៅក្នុងសំណុំរឿង ០០៤។ នៅក្នុងសេចក្តីជូនដំណឹងនេះ ស.ច.ស.អ.ប បានជូនដំណឹង អ៊ឹម ចែម *ច្រើនរឿង ដែលក្នុងចំណោមនោះមានដូចជា* អំពីឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវដែលបានចោទដោយសហព្រះរាជអាជ្ញាអន្តរជាតិ។ ស.ច.ស.អ.ប ក៏បានជូនដំណឹង អ៊ឹម ចែម អំពីតួនាទីដែលគាត់ត្រូវបានចោទប្រកាន់ក្រោមបទថាគាត់បានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះនៅរវាងឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៩[4]។

៣. នៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") បានចុះបញ្ជីករណីខ្វែងយោបល់គ្នាសម្ងាត់ ដោយអនុលោមតាមវិធានផ្ទៃក្នុង ៧២[5]។

---

[4] សំណុំរឿង ០០៤ ឯកសារ D108 *ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ[វិធាន ២១(១((ឃ)]* ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២។

[5] កំណត់ហេតុនៃករណីខ្វែងយោបល់គ្នា ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤។

៤. នៅថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៤ សហមេធាវីរបស់ អ៊ឹម ចែម បានដាក់សំណើសុំចូលពិនិត្យមើលសំណុំរឿង ០០៤ ("សំណើសុំចូលពិនិត្យមើលសំណុំរឿង")[6]។

៥. នៅថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៤ ស.ច.ស.អន្តរជាតិ បានជូនដំណឹង លោក Jonh R. W. D. Jones សហមេធាវីអន្តរជាតិរបស់ អ៊ឹម ចែម ថា មានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់ដែលគាំទ្រការដាក់អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យផ្នែកខ្លះ ហើយ ស.ច.ស.អន្តរជាតិមានបំណងកោះហៅ អ៊ឹម ចែម ឱ្យចូលបង្ហាញខ្លួនលើកដំបូងរវាងថ្ងៃទី ២៥ ដល់ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៤។ លោក Jones បានបញ្ជាក់ថា កិច្ចការរវល់ផ្ទាល់ខ្លួនបានរាំងគាត់មិនឱ្យចូលរួមក្នុងការបង្ហាញខ្លួនលើកដំបូង តាមកាលបរិច្ឆេទទាំងនោះបានទេ ដូច្នេះហើយចំពោះបញ្ហានេះ ស.ច.ស. អន្តរជាតិ បានឆ្លើយតបថា លោក ប៉ិត ស៊ាងលឹម សហមេធាវីជាតិអាចចូលរួមក្នុងការបង្ហាញខ្លួនលើកដំបូងនេះ។

៦. នៅថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៤ លោក Jones បានផ្ញើអ៊ីមែលជូន ស.ច.ស.អន្តរជាតិ ដោយស្នើថា កាលបរិច្ឆេទសម្រាប់ការបង្ហាញខ្លួនលើកដំបូង គួរកំណត់ឡើងវិញដាក់ទៅថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៤។

៧. នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤ សហមេធាវីរបស់ អ៊ឹម ចែម បានផ្ញើលិខិតមួយច្បាប់ជូន ស.ច.ស ដោយធ្វើការស្នើសុំ*ច្រើនរឿង ដែលក្នុងចំណោមនោះមានដូចជា* សុំការបំភ្លឺ"*ថាតើសហចៅក្រមស៊ើបអង្កេតកំពុងតែស្ថិតនៅក្នុងស្ថានភាពនៃការខ្វែងយោបល់គ្នា ឬយ៉ាងណាទាក់ទិននឹងការចេញដីកាកោះហៅ និងធ្វើការចោទប្រកាន់លើកូនក្ដីយើងខ្ញុំ។ យើងខ្ញុំក៏ស្នើឱ្យមានការបញ្ជាក់ឱ្យប្រាកដផងដែរថា បញ្ហានេះនឹងត្រូវដាក់ជាសំណើសុំឱ្យមានការដោះស្រាយដោយអនុលោមតាមវិធាន ៧២ នៃវិធានផ្ទៃក្នុង*"[7]។

---

[6]សំណុំរឿង ០០៤ ឯកសារ D201 *សំណើរបស់អ្នកស្រីអ៊ឹម ចែម សុំដីកាសម្រេចអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿង* ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៤ ដាក់ចូលក្នុងសំណុំរឿងនៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៤។

[7]សំណុំរឿង ០០៤ ឯកសារ A122 *សំណើសុំបញ្ចូលសហចៅក្រមស៊ើបអង្កេតទាំងពីររូបនៅក្នុងទំនាក់ទំនងទាំងអស់ជាផ្លូវការទាក់ទិននឹងអ្នកស្រី អ៊ឹម ចែម និងស្នើថា ការខ្វែងយោបល់គ្នាមួយចំនួនដែលទាក់ទិននឹងការកោះហៅ និងការចោទប្រកាន់លើអ្នកស្រី អ៊ឹម ចែម គួរត្រូវបានបញ្ជូនទៅកាន់អង្គបុរេជំនុំជម្រះ* ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤ ទំព័រ ២។

៨. នៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៤ ស.ច.ស.អន្តរជាតិ បានឆ្លើយតបថា សេចក្ដីសម្រេចបញ្ជូនការខ្វែងយោបល់គ្នាទៅអង្គបុរេជំនុំជម្រះ("អ.ប.ជ") គឺជាឆន្ទានុសិទ្ធិ ហើយលើកលែងតែ និងរហូតដល់ពេលដែលការបញ្ជូននេះត្រូវបានធ្វើឡើង ខ្លឹមសារនៃសៀវភៅចុះបញ្ជីនៃការខ្វែងយោបល់គ្នា នៅតែជាបញ្ហាសម្ងាត់ផ្ទៃក្នុងរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស")។ ស.ច.ស.អន្តរជាតិ ក៏បានបញ្ជាក់ថា "*ទាក់ទងនឹងការខ្វែងយោបល់គ្នាដែលមានយោងនៅក្នុងលិខិតរបស់លោកមេធាវី រយៈពេល ៣០ ថ្ងៃដែលមានចែងនៅក្នុងអនុវិធាន ៧២(៣)បានកន្លងផុតហើយ ដោយគ្មានការបញ្ជូនការខ្វែងយោបល់ណាមួយទៅអង្គបុរេជំនុំជម្រះនោះទេ*"[8]។ នៅថ្ងៃដដែលនោះ ស.ច.ស.អន្តរជាតិ បានជូនដំណឹងសហមេធាវីរបស់ អ៊ឹម ចែម ថា សំណើសុំចូលពិនិត្យមើលសំណុំរឿង នឹងត្រូវឆ្លើយតបក្នុងពេលវេលាសមស្រប។ ស.ច.ស.អន្តរជាតិ ក៏បានជូនដំណឹង សហមេធាវី ថា ដោយអនុលោមតាមវិធានផ្ទៃក្នុង និងដូចបានពន្យល់រួចហើយនៅក្នុងដីកាសម្រេចមួយទៀតនៅក្នុងសំណុំរឿង 00៤ ជនសង្ស័យអាចចូលពិនិត្យមើលសំណុំរឿងបាន នៅពេលណាដែល ស.ច.ស ដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យតែប៉ុណ្ណោះ[9]។

៩. នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៤ ស.ច.ស.អន្តរជាតិ បានផ្ញើលិខិតមួយច្បាប់ជូន សហមេធាវីរបស់អ៊ឹម ចែម ដោយកត់សម្គាល់ថា សហមេធាវី មិនមានពេលអាចចូលរួមក្នុងការបង្ហាញខ្លួនលើកដំបូងនៅខែ មិថុនា បានទេ ហើយក៏បានជូនដំណឹង សហមេធាវី ថា ការបង្ហាញខ្លួនលើកដំបូង ត្រូវបានកំណត់កាលបរិច្ឆេទឡើងវិញដាក់ទៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤។ ស.ច.ស.អន្តរជាតិ ក៏បានជូនដំណឹង សហមេធាវីរបស់ អ៊ឹម ចែម ថា ដីកាកោះនឹងប្រគល់ជូន អ៊ឹម ចែម ដោយផ្ទាល់ក្នុងពេលវេលាសមស្រប ប្រសិនបើនៅត្រឹមថ្ងៃទី ១១ ខែ

---

[8]សំណុំរឿង 00៤ ឯកសារ A122/1 *លិខិតរបស់លោកស្នើសុំឱ្យបញ្ចូលសហចៅក្រមស៊ើបអង្កេតទាំងពីររូបទៅក្នុងទំនាក់ទំនងទាំងអស់ជាផ្លូវការទាក់ទិននឹងអ្នកស្រី អ៊ឹម ចែម និងស្នើថា ការខ្វែងយោបល់គ្នាទាក់ទិននឹងការកោះហៅ និងការចោទប្រកាន់លើអ្នកស្រី អ៊ឹម ចែម គួរត្រូវបានបញ្ជូនទៅកាន់អង្គបុរេជំនុំជម្រះ* ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៤។

[9]សំណុំរឿង 00៤ ឯកសារ D201/1 *ចម្លើយតបទៅនឹងសំណើរបស់អ៊ឹម ចែម សុំដីកាអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿង* ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៤។ *សូមមើល* សំណុំរឿង 00៤ ឯកសារ D121/4 *សេចក្ដីសម្រេចលើសំណើរបស់ក្រុមមេធាវីការពារក្ដី[កោសលុប] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត* ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ៣៦-៣៩។

កក្កដា ឆ្នាំ ២០១៤ សហមេធាវី មិនបានជូនដំណឹង ក.ស.ច.ស ថា ជនសង្ស័យបានអនុញ្ញាតឱ្យសហមេធាវី ទទួលយកដីកាកោះតាងនាមឱ្យគាត់[10]។

១០. នៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៤ សហមេធាវីរបស់អ៊ឹម ចែម បានដាក់ញត្តិស្នើ ស.ច.ស សុំផ្តល់ការស្រាយបំភ្លឺទាក់ទិននឹងការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតអំពី"*ការយល់ឃើញរបស់ពួកគាត់ទៅលើវិធាន ៧២ នៃវិធានផ្ទៃក្នុង ដែលចែងអំពីដំណោះស្រាយលើករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ព្រមទាំងគោលជំហររបស់ពួកគាត់ចំពោះការខ្វែងយោបល់គ្នាដែលពួកគាត់មាននៅក្នុងសំណុំរឿង ០០៤*" ("ញត្តិសុំការស្រាយបំភ្លឺ")[11]។

១១. នៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៤ ដីកាកោះបានប្រគល់ជូន អ៊ឹម ចែម ដោយផ្ទាល់ ដោយកោះហៅគាត់ឱ្យចូលបង្ហាញខ្លួនលើកដំបូង នៅ អ.វ.ត.ក នៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤ ("ដីកាកោះ")[12]។ សហមេធាវីរបស់ អ៊ឹម ចែម ក៏ត្រូវបានកោះហៅឱ្យចូលរួមការបង្ហាញខ្លួនលើកដំបូងនេះផងដែរ[13] ហើយត្រូវបានប្រគល់ជូនសំណៅថតចម្លងមួយច្បាប់នៅថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៤[14]។ នៅក្នុងដីកាកោះទាំងពីរ ស.ច.ស.អន្តរជាតិ បានកត់សម្គាល់ថា ករណីខ្វែងយោបល់គ្នាបានចុះហត្ថលេខានៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤។

១២. នៅថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៤ សហមេធាវីរបស់ អ៊ឹម ចែម បានស្នើសុំចូលពិនិត្យមើលសំណុំរឿង មុនពេលការបង្ហាញខ្លួនលើកដំបូងរបស់ អ៊ឹម ចែម ("លិខិតទីមួយ")[15]។ សហមេធាវីរបស់អ៊ឹម ចែម ក៏បានស្នើទៀតថា កាលបរិច្ឆេទសម្រាប់ការបង្ហាញខ្លួនលើកដំបូង គួរ

---

[10]សំណុំរឿង០០៤ ឯកសារ A122/2 *ការរៀបចំបង្ហាញខ្លួនលើកដំបូងរបស់ជនសង្ស័យ* ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០១៤។

[11]សំណុំរឿង ០០៤ ឯកសារ D204 *ញត្តិរបស់អ៊ឹម ចែម ស្នើសុំឱ្យមានការស្រាយបំភ្លឺទាក់ទិននឹងការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត* ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៤ ទំព័រ ១។

[12]សំណុំរឿង ០០៤ ឯកសារ A150 *ដីកាកោះឱ្យបង្ហាញខ្លួនលើកដំបូង* ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៤។

[13]សំណុំរឿង ០០៤ ឯកសារ A151 *ដីកាកោះហៅមេធាវី* ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៤ ដាក់នៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៤។

[14]សំណុំរឿង ០០៤ ឯកសារ A122/6 *ការឆ្លើយតបទាក់ទងនឹងទម្រង់បែបបទនៃការប្រគល់ដីកាកោះជូនអ៊ឹម ចែម* ថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៤ ដាក់នៅថ្ងៃទី ៤ ខែ សីហា ឆ្នាំ ២០១៤។

[15]សំណុំរឿង ០០៤ ឯកសារ A151/1 *សំណើសុំពិនិត្យមើលសំណុំរឿងមុនពេលអ្នកស្រីអ៊ឹម ចែម បង្ហាញខ្លួនជាលើកដំបូង និងស្នើសុំកំណត់កាលបរិច្ឆេទសាជាថ្មីចំពោះការបង្ហាញខ្លួនជាលើកដំបូង* ថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៤។

ពន្យារពេលដោយសារថា ត្រូវបានចូលពិនិត្យមើលសំណុំរឿងយ៉ាងហោចណាស់ប្រាំថ្ងៃមុនពេលត្រូវសួរយកចម្លើយ តាមលក្ខខណ្ឌតម្រូវនៃវិធានផ្ទៃក្នុង[16]។

១៣. នៅថ្ងៃដដែលនោះ ស.ច.ស.អន្តរជាតិ បានឆ្លើយតបទៅនឹងលិខិតទីមួយ ដោយជូនដំណឹងសហមេធាវីរបស់ អ៊ឹម ចែម ថា កូនក្តីរបស់ពួកគាត់ នឹងមិនត្រូវបានសួរយកចម្លើយទេនៅក្នុងការបង្ហាញខ្លួនលើកដំបូងនេះ ហើយការចូលពិនិត្យមើលសំណុំរឿងនឹងត្រូវអនុញ្ញាតបន្ទាប់ពីការបង្ហាញខ្លួនលើកដំបូងនេះ។ ស.ច.ស.អន្តរជាតិ ក៏បានជូនដំណឹង សហមេធាវីរបស់ អ៊ឹម ចែម ថា ស.ច.ស.អន្តរជាតិ មានពេលពិភាក្សាអំពីកាលបរិច្ឆេទដែលត្រូវសួរយកចម្លើយ អ៊ឹម ចែម[17]។

១៤. នៅក្នុងលិខិតបន្ទាប់មកមួយច្បាប់ទៀត ចុះថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៤("លិខិតទីពីរ") សហមេធាវីរបស់ អ៊ឹម ចែម បានបញ្ជាក់ជាថ្មីអំពីគោលជំហររបស់ខ្លួននៅក្នុងញត្តិសុំការស្រាយបំភ្លឺ គឺថា សហមេធាវី មិនចាត់ទុកថា ដីកាកោះដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ មានសុពលភាពទេ[18]។ សហមេធាវីរបស់ អ៊ឹម ចែម បានបន្ថែមថា ដរាបណាញត្តិសុំការស្រាយបំភ្លឺ មិនទាន់បានសម្រេចនោះ បញ្ហានេះ"*ត្រូវបានធ្វើឱ្យអន្តរាយយ៉ាងខ្លាំងដល់លទ្ធភាពរបស់យើងខ្ញុំក្នុងការផ្តល់ប្រឹក្សាឱ្យបានពេញលេញ និងប្រកបដោយព័ត៌មានលម្អិតជូនដល់[អ៊ឹម ចែម] ឱ្យបានទាន់ពេលវេលា ជាពិសេស ពាក់ព័ន្ធនឹងការកំណត់កាលបរិច្ឆេទដែលបានស្នើឡើងសម្រាប់ការបង្ហាញខ្លួនបឋមនេះតែម្តង*"[19]។ ដូច្នេះ សហមេធាវីបានបដិសេធដីកាកោះរបស់ ស.ច.ស.អន្តរជាតិ ឱ្យចូលរួមក្នុងការបង្ហាញខ្លួនលើកដំបូងដែលបានគ្រោងទុក[20]។

---

[16]*ដូចជើងទំព័រខាងលើ* ទំព័រ ៤។

[17]សំណុំរឿង ០០៤ ឯកសារ A151/1/1 *ចម្លើយរបស់ ស.ច.ស.អន្តរជាតិទៅនឹងសំណើសុំពិនិត្យមើលសំណុំរឿងមុនពេលអ្នកស្រីអ៊ឹម ចែម បង្ហាញខ្លួនជាលើកដំបូង និងស្នើសុំកំណត់កាលបរិច្ឆេទសាជាថ្មីចំពោះការបង្ហាញខ្លួនជាលើកដំបូង* ថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៤។

[18]សំណុំរឿង ០០៤ ឯកសារ A151/2 *ចម្លើយតបទៅនឹងដីកាកោះអញ្ជើញយើងខ្ញុំដើម្បីចូលរួមនៅក្នុងការបង្ហាញខ្លួនបឋមរបស់អ្នកស្រី អ៊ឹម ចែម នៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៤* ថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៤។

[19]*ដូចជើងទំព័រខាងលើ* ទំព័រ ១។

[20]*ដូចជើងទំព័រខាងលើ* ទំព័រ ២។

១៥. នៅថ្ងៃទី ៦ ខែសីហា ឆ្នាំ ២០១៤ នៅក្នុងចម្លើយតបទៅនឹងលិខិតទីពីរ ស.ច.ស.អន្តរជាតិ បានសង្កត់ធ្ងន់ថា អ៊ឹម ចែម និងសហមេធាវីគាត់ តាមផ្លូវច្បាប់ត្រូវតម្រូវឱ្យចូលរួមក្នុងការបង្ហាញខ្លួនលើកដំបូងដែលគ្រោងធ្វើឡើងនៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤[21]។ ស.ច.ស. អន្តរជាតិ បានបញ្ជាក់សាឡើងវិញថា អ.ប.ជ បានទទួលស្គាល់សុពលភាពនៃដីកាកោះដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់។ ស.ច.ស.អន្តរជាតិ ក៏បានរំឭក សហមេធាវីរបស់ អ៊ឹម ចែម ថា ប្រសិនបើសហមេធាវី មិនយល់ស្របតាមគោលជំហរនេះទេ ពួកគាត់មានសិទ្ធិស្វែងរកដំណោះស្រាយផ្លូវច្បាប់នៅក្នុងក្របខណ្ឌវិធានផ្ទៃក្នុង ប៉ុន្តែ ការមិនគោរពតាមដីការបស់តុលាការដោយផ្អែកលើមូលដ្ឋានថា សហមេធាវីមិនយល់ស្របតាមនោះ គឺមិនមែនជាដំណោះស្រាយផ្លូវច្បាប់ដែលមានឡើយ[22]។

១៦. នៅថ្ងៃដដែលនោះ សហមេធាវីរបស់ អ៊ឹម ចែម បានដាក់សំណើបន្ទាន់ស្នើ ស.ច.ស. បញ្ជូនសំណើសុំមោឃភាពដីកាកោះហៅគាត់ និងសហមេធាវីគាត់ ទៅអង្គបុរេជំនុំជម្រះ ("ការស្នើបន្ទាន់")[23]។ នៅក្នុងការស្នើបន្ទាន់នេះ សហមេធាវីរបស់អ៊ឹម ចែម បានអះអាង*ច្រើនរឿងដែលក្នុងចំណោមនោះមានដូចជា* គេអាចសន្និដ្ឋានបានថា មានការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ហើយសហចៅក្រមស៊ើបអង្កេតជាតិ ពុំមានបំណងដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យទេ[24]។ សហមេធាវី បានអះអាងថែមទៀតថា ប្រសិនបើការសន្និដ្ឋាននោះមិនត្រឹមត្រូវទេនោះ ម្ល៉េះសមសហចៅក្រមស៊ើបអង្កេតជាតិបានកែតម្រូវការយល់ឃើញនោះហើយ[25]។

---

[21]សំណុំរឿង០០៤ ឯកសារ A151/2/1 *លិខិតរបស់ ស.ច.ស.អន្តរជាតិ៖ លិខិតរបស់លោកចុះថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៤ ទាក់ទងនឹងដីកាកោះឱ្យចូលរួមការបង្ហាញខ្លួនលើកដំបូងរបស់កូនក្តី* ថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ២។

[22]*ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៣ ដោយដកស្រង់ឯកសារ D208/1/1/2 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់[កោសលុប]ប្រឆាំងដីកាសម្រេចបដិសេធសំណើរបស់គាត់ស្នើសុំព័ត៌មានទាក់ទងនឹងករណីខ្វែងយោបល់គ្នារបស់សហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣* ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥។

[23]សំណុំរឿង ០០៤ ឯកសារ D207 *សំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម ស្នើសុំឱ្យបញ្ជូនសំណើសុំមោឃភាពដីកាកោះហៅអ្នកស្រី និងសហមេធាវីការពារក្តីគាត់ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៤ ទៅអង្គបុរេជំនុំជម្រះ [ការស្នើបន្ទាន់]* ថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០១៤។

[24]ការស្នើបន្ទាន់ កថាខណ្ឌ ២៤។

[25]*ដូចជើងទំព័រខាងលើ*។

១៧. នៅក្នុងលិខិតចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ និងទទួលបានដោយ ស.ច.ស.អន្តរជាតិ នៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤ សហមេធាវីរបស់ អ៊ឹម ចែម បានជូនដំណឹង ស.ច.ស.អន្តរជាតិ *ច្រើនរឿង ដែលក្នុងចំណោមនោះមានដូចជា* ពួកគាត់មានបំណងដាក់បណ្តឹងឧទ្ធរណ៍បន្ទាន់ទៅ អ.ប.ជ ដើម្បីស្នើសុំព្យួរការអនុវត្តដីកាកោះ("សំណើបន្ទាន់")[26]។ សហមេធាវីក៏បានជូនដំណឹង ស.ច.ស.អន្តរជាតិ ទៀតថា ពួកគាត់មិនស្ថិតនៅក្នុងតួនាទីមួយដែលអាចជូនដំណឹងថាតើ អ៊ឹម ចែម នឹងចូលរួមការបង្ហាញខ្លួនលើកដំបូងឬអត់នោះទេ ដោយរង់ចាំសេចក្តីសម្រេចរបស់ អ.ប.ជ លើសំណើបន្ទាន់នោះសិន[27]។

១៨. នៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤ ស.ច.ស.អន្តរជាតិ បានបដិសេធញត្តិសុំការស្រាយបំភ្លឺ និងបានបញ្ជាក់ឡើងវិញថា "*ការអនុវត្តរបស់ ស.ច.ស នៅក្នុងសំណុំរឿង ០០៤ គឺគោរពទាំងស្រុងតាមបទប្បញ្ញត្តិពាក់ព័ន្ធនានា និងស្មារតីទូទៅនៃច្បាប់ដែលចែងអំពីការស៊ើបអង្កេតនៅ អ.វ.ត.ក[...]*"("ដីកាសម្រេចលើការស្រាយបំភ្លឺ")[28]។ នៅថ្ងៃដដែលនោះ អ.ប.ជ បានបដិសេធសំណើបន្ទាន់("សេចក្តីសម្រេចរបស់ អ.ប.ជ")[29] ដោយបានបញ្ជាក់ថា "*អង្គបុរេជំនុំជម្រះ បានបញ្ជាក់នាពេលមុនរួចហើយថា សហព្រះរាជអាជ្ញាម្នាក់ ឬសហចៅក្រមស៊ើបអង្កេតម្នាក់ អាចបំពេញកិច្ចតែម្នាក់ឯងបាន នៅពេលការខ្វែងយោបល់គ្នាបាន ចុះបញ្ជីរួចរាល់នៅក្នុងការិយាល័យសហព្រះរាជអាជ្ញា ឬការិយាល័យសហចៅក្រមស៊ើបអង្កេតតាមករណីសមស្រប និងរយៈពេលនាំយកការខ្វែងយោបល់គ្នា មកចំពោះមុខអង្គបុរេជំនុំជម្រះ បានកន្លងផុត*"[30]។

---

[26]សំណុំរឿង ០០៤ ឯកសារ A151/4 *កិច្ចប្រជុំដែលត្រូវបានកោះឡើងដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Mark HARMON នៅថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១៤* ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ ដាក់នៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤ ទំព័រ២។

[27]*ដូចជើងទំព័រខាងលើ* ។

[28]សំណុំរឿង ០០៤ ឯកសារ D204/2 *ដីកាសម្រេចលើញត្តិរបស់ជនសង្ស័យស្នើសុំឱ្យមានការស្រាយបំភ្លឺទាក់ទិននឹងការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត* ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ១១។

[29]សំណុំរឿង ០០៤ ឯកសារ A122/6.1/2 *សេចក្តីសម្រេចលើសំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម សុំព្យួរការអនុវត្តដីកាកោះហៅអ្នកស្រីឱ្យមកបង្ហាញខ្លួនជាលើកដំបូង* ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤។

[30]សំណុំរឿង ០០៤ ឯកសារ A122/6.1/3 *សេចក្តីសម្រេចលើសំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម សុំព្យួរការអនុវត្តដីកាកោះហៅអ្នកស្រីឱ្យមកបង្ហាញខ្លួនជាលើកដំបូង* ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ១៤។

១៩. នៅថ្ងៃដដែលនេះ សហមេធាវីអន្តរជាតិរបស់ អ៊ឹម ចែម បានផ្ញើអ៊ីមែល និងទូរសព្ទមក ស.ច.ស. អន្តរជាតិ ដោយជូនដំណឹងថា ដោយគិតទៅលើសេចក្តីសម្រេចរបស់ អ.ប.ជ និងបានប្រើប្រាស់អស់នូវមធ្យោបាយផ្លូវច្បាប់របស់ខ្លួន អ៊ឹម ចែម នឹងចូលបង្ហាញខ្លួនលើកដំបូង[31]។ ហេតុនេះ ការបង្ហាញខ្លួនលើកដំបូងនឹងគ្រោងធ្វើឡើងនៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤ ហើយវិធានការផ្លូវច្បាប់ ដោយសារ អ៊ឹម ចែម មិនបានបង្ហាញខ្លួន ត្រូវបានពន្យារពេល[32]។

២០. នៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៤ សហមេធាវីរបស់ អ៊ឹម ចែម បានជូនដំណឹង ស.ច.ស. អន្តរជាតិ ថា កូនក្តីរបស់ខ្លួន មិនមានចេតនាបង្ហាញខ្លួនតាមដីកាកោះដែលចេញដោយ ស.ច.ស.អន្តរជាតិ តែម្នាក់ឯងនោះទេ[33]។

២១. នៅថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៤ បន្ទាប់ពី អ៊ឹម ចែម ខកខានមិនបានគោរពតាមដីកាកោះមក ស.ច.ស.អន្តរជាតិ បានចេញដីកានាំខ្លួនដើម្បីធានាថា គាត់ចូលបង្ហាញខ្លួនលើកដំបូងនៅ អ.វ.ត.ក("ដីកានាំខ្លួន")[34]។ នៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤ ដីកានាំខ្លួនបានប្រគល់ជូននគរបាលយុត្តិធម៌របស់ប្រទេសកម្ពុជាដើម្បីអនុវត្ត[35]។

២២. នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ ស.ច.ស.អន្តរជាតិ បានបដិសេធការស្នើសុំបន្ទាន់ ដោយផ្អែកលើមូលដ្ឋានថា ក្នុងនាមជាជនសង្ស័យ អ៊ឹម ចែម មិនមានសិទ្ធិស្នើឱ្យ ស.ច.ស ដាក់ពាក្យសុំមោឃភាពកិច្ចស៊ើបសួរបានឡើយ[36]។ បន្ថែមពីលើនេះទៀត សំណើសុំព្យួរដីកាកោះត្រូវបានសម្រេចថាអស់សុពលភាព ដោយឃើញថា អ៊ឹម ចែម មានចេតនាមិនចូលបង្ហាញខ្លួននៅក្នុងការបង្ហាញខ្លួនលើកដំបូងដែលបានគ្រោងទុក និងដោយគិតទៅលើការជូនដំណឹងពី

[31]សំណុំរឿង ០០៤ ឯកសារ A150/2 *កំណត់សម្គាល់របស់ ស.ច.ស.អន្តរជាតិ ទាក់ទងនឹងការបង្ហាញលើកដំបូងរបស់អ៊ឹម ចែម* ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤។ សំណុំរឿង ០០៤ ឯកសារ A150/2/2.1 *ការឆ្លើយឆ្លងអ៊ីមែលរវាងស.ច.ស.អន្តរជាតិជាមួយលោក John Jones ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤* ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៤។

[32]*ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៤។

[33]*ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៦។

[34]សំណុំរឿង ០០៤ ឯកសារ C1 *ដីកាបង្គាប់ឱ្យនាំខ្លួន* ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៤។

[35]សំណុំរឿង ០០៤ ឯកសារ C1.1 *របាយការណ៍ស្តីពីការប្រគល់ដីកាបង្គាប់ឱ្យនាំខ្លួនជូននគរបាលយុត្តិធម៌* ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤។

[36]សំណុំរឿង ០០៤ ឯកសារ D207/1 *ដីកាសម្រេចលើសំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម ស្នើសុំឱ្យបញ្ជូនសំណើសុំមោឃភាពដីកាកោះហៅអ្នកស្រី និងសហមេធាវីការពារក្តីគាត់ទៅអង្គបុរេជំនុំជម្រះ* ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤។

សហមេធាវីរបស់គាត់ដែលថា គាត់នឹងមិនចូលបង្ហាញខ្លួននៅ អ.វ.ត.ក ដោយស្ម័គ្រចិត្តឡើយ និងដោយគិតទៅលើការបដិសេធរបស់ អ.ប.ជ ដែលច្រានចោលសំណើសុំព្យួរនេះ[37]។

២៣. នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៤ ស.ច.ស.អន្តរជាតិ បានជួបជាមួយតំណាងម្នាក់របស់នគរបាលយុត្តិធម៌ ដោយពិភាក្សាអំពីបច្ចុប្បន្នភាពទាក់ទងនឹងវឌ្ឍនភាពនៅក្នុងការអនុវត្តដីកានាំខ្លួន។ តំណាងនគរបាលយុត្តិធម៌រូបនោះ បានសួរ ស.ច.ស.អន្តរជាតិ ថាតើ ដីកានាំខ្លួនដែលមិនបានចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតជាតិ មានសុពលភាពដែរឬអត់។ ស.ច.ស.អន្តរជាតិ បានរំឭក តំណាងរូបនោះ ថា គាត់បានបញ្ជាក់រួចហើយអំពីសុពលភាពនៃដីកានាំខ្លួន នៅថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៤ បន្ទាប់មក ស.ច.ស.អន្តរជាតិ បានពន្យល់អំពីមូលដ្ឋានសម្រាប់សុពលភាពនៃដីកានាំខ្លួន ហើយបានផ្តល់ជូនគាត់នូវសំណៅកោសលុបមួយច្បាប់នៃសេចក្តីសម្រេចរបស់ អ.ប.ជ ដែលក្នុងនោះ អំណាចរបស់ ស.ច.ស.អន្តរជាតិក្នុងការចេញដីកាដោយឯកតោភាគី ត្រូវបានបញ្ជាក់។ តំណាងនគរបាលយុត្តិធម៌រូបនោះ បានបញ្ជាក់ថា គាត់នឹងបញ្ជូនសំណៅមួយច្បាប់នៃសេចក្តីសម្រេចរបស់ អ.ប.ជ ជូនប្រធានគណៈកម្មការសន្តិសុខប្រចាំ អ.វ.ត.ក។ គាត់ក៏បានបញ្ជាក់ទៀតថា គណៈកម្មការសន្តិសុខប្រចាំ អ.វ.ត.ក អាចទាក់ទងសហចៅក្រមស៊ើបអង្កេតជាតិដើម្បីសាកសួរអំពីសុពលភាពនៃដីកានាំខ្លួន។ ស.ច.ស.អន្តរជាតិ បានបញ្ចប់កិច្ចប្រជុំនេះ ដោយស្នើ តំណាងនគរបាលយុត្តិធម៌ឱ្យជូនដំណឹងគាត់ឱ្យបានឆាប់រហ័សអំពីបញ្ហាណាមួយទៀតដែលអាចប៉ះពាល់ដល់ការអនុវត្តដីកានាំខ្លួនឱ្យបានឆាប់រហ័ស។ តំណាងនគរបាយលយុត្តិធម៌ បានឆ្លើយថា មិនមានបញ្ហាផ្សេងទៀតទេ ហើយដីកានាំខ្លួននឹងត្រូវអនុវត្ត នៅពេលណាដែលសុពលភាពនៃដីកានាំខ្លួននេះត្រូវបានបញ្ជាក់។

២៤. នៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ ស.ច.ស.អន្តរជាតិ បានជួបប្រជុំលើកទីពីរជាមួយតំណាងនគរបាលយុត្តិធម៌ ដែលបានជូនដំណឹង ស.ច.ស.អន្តរជាតិ ថា ស្ថានភាពសន្តិសុខនៅតំបន់លំនៅដ្ឋានរបស់ អ៊ឹម ចែម មានបញ្ហា។ គាត់បានស្នើថា ក.ស.ច.ស គួររៀបចំធ្វើសកម្មភាពផ្សព្វផ្សាយនៅតំបន់នោះដើម្បីធ្វើឱ្យប្រជាជនមូលដ្ឋាននៅទីនោះជឿជាក់ថា ក.ស.ច.ស មិនមានបំណងធ្វើការចាប់ខ្លួនមនុស្សច្រើននាក់នៅតំបន់នោះទេ។ តំណាងនគរបាលយុត្តិធម៌ ក៏

[37] *ដូចដើងទំព័រខាងលើ* កថាខណ្ឌ ៣៥។

បានបន្ថែមទៀតផងដែរថា ការពិតដែលថា ដីកានាំខ្លួនបានចុះហត្ថលេខាតែ ស.ច.ស. អន្តរជាតិតែម្នាក់ឯងនោះ ពុំមែនជាការរាំងស្ទះដល់ការអនុវត្តដីកានាំខ្លួននោះទេ។

២៥. នៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤ ស.ច.ស.អន្តរជាតិ បានទទួលសារមួយពីតំណាងនគរបាលយុត្តិធម៌ ដែលបានកំណត់អត្តសញ្ញាណតំបន់នានាដែលសកម្មភាពផ្សព្វផ្សាយគួររៀបចំធ្វើឡើង។

២៦. នៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៤ ស.ច.ស.អន្តរជាតិ បានជួបប្រជុំម្តងទៀតជាមួយតំណាងម្នាក់របស់នគរបាលយុត្តិធម៌ ហើយបានយល់ស្របលើកាលបរិច្ឆេទសម្រាប់រៀបចំសកម្មភាពផ្សព្វផ្សាយ។ កម្មវិធីផ្សព្វផ្សាយដាច់ដោយឡែកចំនួនប្រាំបួន ត្រូវបានរៀបចំធ្វើឡើងដោយសមាជិកបុគ្គលិករបស់ ក.ស.ច.ស រួមមាន ស.ច.ស.អន្តរជាតិ ផងដែរ នៅរវាងថ្ងៃទី ១១ ដល់ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៤ នៅក្នុងខេត្តឧត្តរមានជ័យ បាត់ដំបង និងប៉ៃលិន[38]។

២៧. នៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ សហមេធាវីរបស់ អ៊ឹម ចែម បាដាក់*ទឡ្ហីករណ៍បន្ថែមលើសំណើរបស់អ្នកស្រី អ៊ឹម ចែម សុំដីកាសម្រេចអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿង* ("ទឡ្ហីករណ៍បន្ថែមលើសំណើសុំចូលពិនិត្យមើលសំណុំរឿង")។ សហមេធាវីបានកត់សម្គាល់ថា សំណើសុំចូលពិនិត្យមើលសំណុំរឿងមិនទាន់ត្រូវបានសម្រេចនៅឡើយទេ បន្ទាប់មកសហមេធាវីបានបញ្ជាក់ថា ការឆ្លើយតបទៅនឹងសំណើនោះ គឺជាការបន្ទាន់ ដោយសារមានការវិវឌ្ឍចំនួនពីរ គឺ ការចេញផ្សាយគម្រោងបញ្ចប់ផែនការការងាររបស់ អ.វ.ត.ក ដែលស្តែងឱ្យឃើញថា អ៊ឹម ចែម មានពេលវេលានៅសល់តិចតួចដើម្បីចូលរួមការស៊ើបអង្កេត និងអង្គហេតុដែលថា ស.ច.ស.អន្តរជាតិ បានកោះហៅ អ៊ឹម ចែម ឱ្យចូលបង្ហាញខ្លួនលើកដំបូង ដែលប្រការនេះបើតាម សហមេធាវី បានបង្ហាញថា អ៊ឹម ចែម ស្ថិតក្នុងស្ថានភាពជាជនត្រូវចោទដែលមានសិទ្ធិចូលពិនិត្យមើលសំណុំរឿង "*វៀរលែងតែបញ្ហាទម្រង់ការប៉ុណ្ណោះ*"[39]។

---

[38]*សូមមើល* របាយការណ៍តុលាការរបស់ អ.វ.ត.ក ខែ ធ្នូ ឆ្នាំ ២០១៤ ទំព័រ ៣ [ភាសាអង់គ្លេស]៖ http://www.eccc.gov.kh/en/publication/court-report-december-2014។

[39]សំណុំរឿង ០០៤ ឯកសារ D201/2 *ទឡ្ហីករណ៍បន្ថែមលើសំណើរបស់អ្នកស្រី អ៊ឹម ចែម សុំដីកាសម្រេចអនុញ្ញាតឱ្យចូលពិនិត្យមើលសំណុំរឿង* ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ កថាខណ្ឌ ២។

២៨. នៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៤ សមាជិកបុគ្គលិកពីរនាក់របស់ ក.ស.ច.ស បានជួបប្រជុំជាមួយតំណាងម្នាក់របស់នគរបាលយុត្តិធម៌ ដើម្បីពិភាក្សាអំពីវឌ្ឍនភាពនៅក្នុងការអនុវត្តដីកានាំខ្លួន។ បុគ្គលិកទាំងនោះត្រូវបានជូនដំណឹងថា នគរបាលយុត្តិធម៌ មិនទាន់បានធ្វើការស្ទង់មតិក្រោយសកម្មភាពផ្សព្វផ្សាយទេ។ តំណាងនគរបាលយុត្តិធម៌រូបនោះ មិនស្ថិតនៅក្នុងតួនាទីដែលអាចបញ្ជាក់ថាតើនៅពេលណាដែលដីកានាំខ្លួនអាចអនុវត្តបានឡើយ។ តំណាងនគរបាលយុត្តិធម៌រូបនោះ បានបញ្ជាក់ថា សេចក្ដីសម្រេចចុងក្រោយចំពោះរឿងនេះ គឺស្ថិតនៅលើគណៈកម្មការសន្តិសុខប្រចាំ អ.វ.ត.ក។

២៩. នៅថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥ ស.ច.ស.អន្តរជាតិ បានសរសេរលិខិតមួយច្បាប់ជូនប្រធានគណៈកម្មការសន្តិសុខប្រចាំ អ.វ.ត.ក ហើយលិខិតនោះបានប្រគល់ជូននៅថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៥។ នៅក្នុងលិខិតនោះ ស.ច.ស.អន្តរជាតិ បានកត់សម្គាល់ថា កិច្ចខិតខំប្រឹងប្រែងដើម្បីធានា អ៊ឹម ចែម និងជនសង្ស័យម្នាក់ទៀត បានចូលបង្ហាញខ្លួនលើកដំបូងនៅ អ.វ.ត.ក គឺមិនបានទទួលជោគជ័យទេ ទោះបីជារយៈពេលជាងពីរខែបានកន្លងផុតទៅហើយចាប់តាំងពីកម្មវិធីផ្សព្វផ្សាយទាំងនោះបានរៀបចំធ្វើរួចហើយក៏ដោយ។ ស.ច.ស.អន្តរជាតិ ក៏កត់សម្គាល់ថា មិនច្បាស់ថាតើដីកានាំខ្លួននឹងត្រូវអនុវត្តនៅពេលណានោះទេ ហើយការពន្យារពេលបន្ថែមទៀតនឹងប៉ះពាល់ដល់ប្រយោជន៍យុត្តិធម៌ និងសិទ្ធិរបស់ អ៊ឹម ចែម តាម មាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រួមបញ្ចូលទាំងសិទ្ធិចូលរួមការស៊ើបអង្កេត និងសិទ្ធិទទួលបានការជំនុំជម្រះដោយឥតពន្យារពេលយូរហួស។ ស.ច.ស. អន្តរជាតិ ក៏បានបញ្ជាក់ថា ការពន្យារពេលបន្ថែមទៀតក៏នឹងប៉ះពាល់យ៉ាងធ្ងន់ធ្ងរផងដែរដល់សិទ្ធិរបស់ជនរងគ្រោះ និងប្រជាជនកម្ពុជាដើម្បីទទួលបានយុត្តិធម៌ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ។ ស.ច.ស.អន្តរជាតិ បានបញ្ជាក់ថា គាត់នឹងបន្តកិច្ចដំណើរការនីតិវិធីដាក់ អ៊ឹម ចែម ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ដោយសារថា ការពន្យារពេលថែមទៀតអាចបង្កើតឲ្យមានហានិភ័យមិនអាចទទួលយកបាន ប្រសិនបើ អ៊ឹម ចែម មិនបានបង្ហាញខ្លួននៅ អ.វ.ត.ក នៅត្រឹមថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឬក៏មិនត្រូវបាននាំខ្លួននៅត្រឹមកាលបរិច្ឆេទនោះទេ។ ស.ច.ស.អន្តរជាតិ បានជូនដំណឹងទៅ ប្រធានគណៈកម្មការសន្តិសុខ ថា គាត់យល់ឃើញថា នេះគឺជាដំណើរការនៃវិធានការដែលអាចកាត់បន្ថយហានិភ័យតែមួយគត់ ដោយសារគ្មានចំណាត់ការពីនគរបាល

យុត្តិធម៌[40]។

៣០. កាលបរិច្ឆេទថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥ បានកន្លងផុតហើយ ដោយ អ៊ឹម ចែម មិនបានចូលបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក ទេ ហើយដីកានាំខ្លួនក៏មិនបានអនុវត្តដែរ។

**ច្បាប់ជាធរមាន**

**វិធានស្ដីពីនីតិវិធីដែលអាចអនុវត្តទៅលើការស៊ើបអង្កេតរបស់តុលាការនៅ អ.វ.ត.ក**

៣១. មាត្រា ២៣ ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ចែងអំពីផ្នែកពាក់ព័ន្ធថា៖

> "រាល់ការស៊ើបអង្កេត គឺជាការទទួលខុសត្រូវរួមគ្នារបស់ចៅក្រមពីរនាក់ ម្នាក់ជាកម្ពុជា និងម្នាក់ទៀតជាបរទេស ដែលហៅថា "សហចៅក្រមស៊ើបអង្កេត" ដោយអនុវត្តតាមនីតិវិធីដែលនៅជាធរមាន។ ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ ឬ ប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ"។

**កាតព្វកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការផ្ដល់ជំនួយដល់ ស.ច.ស**

៣២. មាត្រា ២៥ នៃកិច្ចព្រមព្រៀង អ.វ.ត.ក ចែងថា៖

> "រាជរដ្ឋាភិបាលនឹងអនុវត្តដោយគ្មានការពន្យារពេលតាមការស្នើសុំជំនួយរបស់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា ឬអង្គជំនុំជម្រះវិសាមញ្ញ ឬក៏បញ្ជារបស់ពួកគេរួមមាន ប៉ុន្តែមិនមែនត្រឹមតែ៖
>
> ក-រកអត្តសញ្ញាណ និងទីកន្លែងរបស់បុគ្គលណាមួយ។
>
> ខ-ផ្ដល់ឯកសារ។

---

[40]សំណុំរឿង ០០៤ ឯកសារ D238 *លិខិតផ្ញើជូនប្រធានគណៈកម្មការសន្តិសុខប្រចាំ អ.វ.ត.ក* ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥ ដាក់នៅថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៥។

គ-ចាប់ខ្លួន ឬឃុំខ្លួនបុគ្គលណាមួយ។

ឃ-បញ្ជូនជនជាប់ចោទ មកកាន់អង្គជំនុំជម្រះវិសាមញ្ញ"។

៣៣. មាត្រា ២៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងអំពីផ្នែកពាក់ព័ន្ធថា៖

"ក្នុងការអនុវត្តភារកិច្ចនេះ សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការជួយឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជាបាន ប្រសិនបើយល់ឃើញថាសមស្រប និងមានប្រយោជន៍ដល់ការស៊ើបអង្កេត ហើយការជួយឧបត្ថម្ភនេះត្រូវតែបានផ្តល់ជូន"។

**កាតព្វកិច្ចរបស់នគរបាលយុត្តិធម៌ក្នុងការផ្តល់ជំនួយដល់ ស.ច.ស**

៣៤. វិធានផ្ទៃក្នុង ១៥ ចែងអំពីផ្នែកពាក់ព័ន្ធថា៖

"នគរបាលយុត្តិធម៌ គឺជាមន្ត្រីជំនួយរបស់អង្គជំនុំជម្រះវិសាមញ្ញ។ មន្ត្រីទាំងនេះអនុវត្តការស៊ើបអង្កេតនៅទូទាំងប្រទេសកម្ពុជា ក្រោមការណែនាំតែពីសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះ តាមករណីសមស្រប ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុងនេះ។ នៅក្នុងការបំពេញមុខងាររបស់ខ្លួននគរបាលយុត្តិធម៌មិនត្រូវស្វែងរក ឬ ទទួលបញ្ជាពីជនណាផ្សេងទៀតឡើយ"។

សហព្រះរាជអាជ្ញាត្រូវដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់នគរបាលយុត្តិធម៌រហូតដល់ការស៊ើបសួរ ត្រូវបានចាប់ផ្តើមដំណើរការ។ នៅពេលការស៊ើបសួរចាប់ផ្តើមដំណើរការ នគរបាលយុត្តិធម៌ត្រូវបំពេញភារកិច្ចរបស់ខ្លួនតាមការណែនាំរបស់សហចៅក្រមស៊ើបអង្កេត។

៣៥. វិធានផ្ទៃក្នុង ៤៥ ចែងអំពីផ្នែកពាក់ព័ន្ធថា៖

រាល់ដីកាបង្គាប់ឲ្យនាំខ្លួន ដីកាបង្គាប់ឲ្យឃុំខ្លួន និងដីកាបង្គាប់ឲ្យចាប់ខ្លួនទាំងអស់ ត្រូវអនុវត្តដោយនគរបាលយុត្តិធម៌។ ដីកាដើមត្រូវប្រគល់ឲ្យភ្លាមដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលមានភារកិច្ចត្រូវទទួលអនុវត្តដីកានេះ។ ក្នុងករណីបន្ទាន់ ត្រូវជូនដំណឹងអំពីដីកានេះទៅដល់មន្ត្រីនគរបាលយុត្តិធម៌ ដោយប្រើប្រាស់គ្រប់មធ្យោបាយ

ទាំងអស់ ហើយដីកាដើមត្រូវប្រគល់ឱ្យនគរបាលយុត្តិធម៌ ក្នុងរយៈពេល ៤៨ (សែសិបប្រាំបី) ម៉ោង។

៣៦. វិធានផ្ទៃក្នុង ៦២ ចែងអំពីផ្នែកពាក់ព័ន្ធថា៖

"សហចៅក្រមស៊ើបអង្កេត អាចចេញដីកាចាត់ឱ្យស៊ើបសួរជំនួសទៅឱ្យអ្នកស៊ើបអង្កេតនៃការិយាល័យរបស់ខ្លួន ឬនគរបាលយុត្តិធម៌ដើម្បីបំពេញកិច្ចស៊ើបសួរ។ ប៉ុន្តែមានតែនគរបាលយុត្តិធម៌ទេ ដែលមានអំណាចក្នុងការអនុវត្តន៍វិធានការចាប់បង្ខំ"។

**ការដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យនៅក្នុងការស៊ើបអង្កេតរបស់តុលាការនៅ អ.វ.ត.ក**

៣៧. វិធានផ្ទៃក្នុង ២១(១)(ឃ) ចែងថា៖

"ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ។ ជនទាំងនេះមានសិទ្ធិទទួលដំណឹងអំពីបទល្មើស ដែលចោទប្រកាន់ចំពោះខ្លួន និងមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន ហើយនិងនៅក្នុងគ្រប់ដំណាក់កាល ទាំងអស់នៃកិច្ចដំណើរការនីតិវិធីត្រូវផ្តល់ព័ត៌មានដល់គេ អំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប"។

៣៨. វិធានផ្ទៃក្នុង ៥៥(៤)ចែងថា៖

"សហចៅក្រមស៊ើបអង្កេត មានអំណាចបើកការស៊ើបសួរប្រឆាំងនឹងជនទាំងឡាយណា ដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ សហចៅក្រមស៊ើបអង្កេតអាចបើកកិច្ចស៊ើបសួរផងដែរ ចំពោះបុគ្គលគ្រប់រូបដែលមានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា បុគ្គលនោះអាចជាអ្នកទទួលខុសត្រូវក្នុងការប្រព្រឹត្តបទឧក្រិដ្ឋដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ទោះបីជាបុគ្គលទាំងនោះមិនមានឈ្មោះក្នុងដីកាក៏ដោយ។ ក្នុងករណីចុងក្រោយនេះ សហចៅក្រមស៊ើបអង្កេតត្រូវសួរយោបល់សហព្រះរាជអាជ្ញាមុនពេលដាក់បុគ្គលនោះឱ្យស្ថិតនៅក្រោមការពិនិត្យ"។

## ការដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*

<u>វិធានផ្ទៃក្នុង</u>

៣៩. វិធានផ្ទៃក្នុង ៨១(១) ចែងពីគោលការណ៍ដែលថា *"ការជំនុំជម្រះត្រូវតែធ្វើឡើងដោយមានវត្តមានរបស់ជនជាប់ចោទ"* លើកលែងតែកាលៈទេសៈពិសេសដែលចែងខុសពីវិធានផ្ទៃក្នុង ៨១។ នេះគឺជាការដាក់កំហិតយ៉ាងច្បាស់ទៅលើការទទួលយកជាទូទៅនូវការជំនុំជម្រះ*ដោយកំបាំងមុខ*តាមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[41]។ ទោះយ៉ាងណា ការដាក់កំហិតនេះមានលក្ខណៈកម្រិត ពីព្រោះថា ការដាក់កំហិតនេះអនុវត្តតែទៅលើ*ជនជាប់ចោទ* នៅក្នុងដំណាក់កាលជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីតែប៉ុណ្ណោះ (ជនជាប់ចោទ គឺជាបុគ្គលដែលត្រូវចោទប្រកាន់ដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ)[42]។ វិធានផ្ទៃក្នុង ៨១ គ្រាន់តែតម្រូវឱ្យមានវត្តមានរបស់ជនជាប់ចោទ នៅក្នុងសវនាការបឋមនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងតែប៉ុណ្ណោះ ដូចបានបញ្ជាក់នៅក្នុងវិធាន ៨១(៤)។ វិធានផ្ទៃក្នុង ៨១(៣) បញ្ជាក់យ៉ាងច្បាស់ថា វត្តមានរបស់ជនជាប់ចោទនៅក្នុងសវនាការបឋមនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង គឺជាលក្ខខណ្ឌតម្រូវមួយដែលចាំបាច់ដើម្បីបន្តសវនាការជាបន្តបន្ទាប់។

៤០. វិធានផ្ទៃក្នុង មិនមានចែងពីការដាក់កំហិតដូចគ្នានេះទេទាក់ទងនឹងដំណាក់កាលស៊ើបអង្កេតនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌនៅចំពោះមុខ អ.វ.ត.ក។ វិធានផ្ទៃក្នុង ៥៧ មិនដាក់បុរេលក្ខខណ្ឌចាំបាច់ថា [ជនសង្ស័យ]ត្រូវតែមានវត្តមានជាក់ស្តែងដើម្បីឱ្យ ស.ច.ស បន្តកិច្ចដំណើរការនីតិវិធីដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យទេ។ ទោះជាយ៉ាងណាក្តី វិធានផ្ទៃក្នុង មិនមានបទប្បញ្ញត្តិណាដែលចែងពីការដាក់ឱ្យស្ថិតក្រោមការពិនិត្យទៅលើជនសង្ស័យណាដែលបានបដិសេធមិនចូលបង្ហាញខ្លួនលើកដំបូងអនុលោមតាមវិធានផ្ទៃក្នុង ៥៧ ហើយក៏មិនអាចឱ្យចូលបង្ហាញខ្លួនតាមមធ្យោបាយបង្ខំដែរ។

៤១. វិធានផ្ទៃក្នុងគឺជាប្រភពឯកសារចម្បងស្តីពីនីតិវិធីនៅ អ.វ.ត.ក ប៉ុន្តែនៅពេលដែលបញ្ហាណាមួយមិនមានចែងនៅក្នុងវិធានផ្ទៃក្នុង *នោះ* ស.ច.ស ត្រូវតែសម្រេចថាតើ បញ្ហានោះមានចែង

---

[41] *សូមមើល* មាត្រា ៣៣៣, ៣៥៣, ៣៦១ និង ៣៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[42] *សូមមើល* សន្ទានុក្រមក្នុងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។

នៅក្នុងច្បាប់កម្ពុជាដែរឬអត់[43]។ ស.ច.ស អាចស្វែងរកការណែនាំផ្នែកវិធានស្ដីពីនីតិវិធីដែលបានបង្កើតឡើងនៅថ្នាក់អន្តរជាតិក្នុងករណីដែលក្នុងអំឡុងពេលស៊ើបអង្កេត មានបញ្ហាណាមួយកើតឡើង ហើយមិនមានចែងនៅក្នុងវិធានផ្ទៃក្នុង ឬក្នុងច្បាប់កម្ពុជា ក្នុងករណីដែលមានភាពមិនច្បាស់លាស់ទាក់ទងនឹងការបកស្រាយ ឬការអនុវត្ត ឬក៏ទាក់ទងនឹងសង្គតិភាពជាមួយបទដ្ឋានអន្តរជាតិ[44]។

៤២. ដូច្នេះ នៅពេលដែលពិចារណាដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ស.ច.ស.អន្តរជាតិ នឹងពិនិត្យថាតើនីតិវិធីនេះមានចែងនៅក្នុងច្បាប់កម្ពុជាដែរឬអត់។ បន្ទាប់មក ប្រសិនបើចាំបាច់ ការណែនាំបន្ថែមទៀតនឹងត្រូវស្វែងរកទាក់ទងនឹងវិធានស្ដីពីនីតិវិធីដែលបានបង្កើតឡើងនៅថ្នាក់អន្តរជាតិ។

## ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា

៤៣. ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនមានបទប្បញ្ញត្តិដែលចែងច្បាស់លាស់អំពីការដាក់ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*ទេ។ ទោះជាយ៉ាងណាក្ដី ក្រមនេះអនុញ្ញាត ហើយក៏មានបទប្បញ្ញត្តិច្បាស់លាស់ដែលចែងអំពីការជំនុំជម្រះ និងការប្រកាសសាលក្រម*ដោយកំបាំងមុខ*ដែរ[45]។ ក្នុងចំណោមបទប្បញ្ញត្តិទាំងនេះ មាត្រា ៣៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចំណងជើង *"ការស្វែងរកពិតក្នុងករណីអវត្តមានរបស់ជនជាប់ចោទ"* ចែងថា *"ទោះបីជាជនជាប់ចោទ អវត្តមានក៏ដោយ តុលាការត្រូវតែស្វែងរកឱ្យឃើញការពិត ស្ដាប់ចម្លើយភាគីដទៃទៀត សាក្សី និងពិនិត្យវត្ថុតាង"*។ ការស្វែងរកការពិតក៏ជាភារកិច្ចចម្បងដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ ស.ច.ស នៅអំឡុងពេលស៊ើបអង្កេតនៅ អ.វ.ត.ក[46]។

---

[43] សំណុំរឿង 00២ ឯកសារ D55/I/8 *សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព* ថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២00៨ កថាខណ្ឌ ១៤-១៥។

[44] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិជាមួយរាជរដ្ឋាភិបាលកម្ពុជា ("កិច្ចព្រមព្រៀង អ.វ.ត.ក") មាត្រា ១២(១)។ ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក មាត្រា ២៣ ថ្មី។ វិធាន ២ នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* សំណុំរឿង 00១ ឯកសារ E188 សាលក្រម ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២0១0 កថាខណ្ឌ ៣៥។

[45] *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៣៣៣, ៣៥១, ៣៦១ និង ៣៦២។

[46] *សូមមើល* មាត្រា ២៣ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង ៥៥(៥)។

៤៤. ស.ច.ស.អន្តរជាតិ មិនអាចចូលពិនិត្យមើលឯកសារកំណត់ហេតុនៃកិច្ចដំណើរការនីតិវិធី *ដោយកំបាំងមុខ* នៅក្នុងតុលាការនៃព្រះរាជាណាចក្រកម្ពុជាទេ។ ទោះជាយ៉ាងណាក្តី ការត្រួតពិនិត្យមើលអត្ថបទសារព័ត៌មានដែលបានចេញផ្សាយរវាងឆ្នាំ ២០១០ ដល់ឆ្នាំ ២០១៤ បង្ហាញឱ្យឃើញថា តាមពិត កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ*ដោយកំបាំងមុខ* ត្រូវបានអនុវត្តនៅក្នុងតុលាការជាតិ[47]។ ស.ច.ស.អន្តរជាតិ ពឹងផ្អែកលើអត្ថបទសារព័ត៌មានទាំងនេះក្នុងគោលបំណងតែមួយគត់ដើម្បីបញ្ជាក់ថា កិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ* បានអនុវត្តនៅក្នុងប្រទេសកម្ពុជា។

៤៥. ដោយផ្អែកលើក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងការអនុវត្តរបស់តុលាការ ស.ច.ស.អន្តរជាតិ ជឿជាក់ថា កិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ* ត្រូវបានអនុញ្ញាតតាមច្បាប់កម្ពុជា[48]។

៤៦. ទោះបីជាការជំនុំជម្រះ*ដោយកំបាំងមុខ* អាចអនុវត្តបានតាមច្បាប់កម្ពុជាក៏ដោយ ក៏វិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនមានបទប្បញ្ញត្តិដែលចែងឱ្យបានច្បាស់អំពីការ

---

[47] ឌី ខែមបូឌា ដេលី *តុលាការកាត់ទោសមនុស្សប្រាំមួយនាក់ ប្រាំនាក់ដោយកំបាំងមុខ ចំពោះការធ្វើឃាតអ្នកសារព័ត៌មាន* ថ្ងៃទី១២ ខែ វិច្ឆិកា ឆ្នាំ ២០១៤៖ https://www.cambodiadaily.com/news/court-sentences-six-five-in-absentia-for-journalists-murder-72121/។ វិទ្យុអាស៊ីសេរី *តុលាការកម្ពុជា តម្កល់ទោសអតីតអភិបាលដែលរត់គេចខ្លួន* ថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១៣៖ http://www.rfa.org/english/news/cambodia/appeal-11042013143446.html។ សារព័ត៌មាន The New York Times *ប្រទេសកម្ពុជា៖ មេដឹកនាំគណបក្សប្រឆាំង ត្រូវបានផ្តន្ទាទោសដោយកំបាំងមុខ* ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១០៖ http://www.nytimes.com/2010/09/24/world/asia/24briefs-Cambodia.html?_r=0។ សារព័ត៌មាន South China Morning Post *អតីតអភិបាលនៅកម្ពុជាត្រូវបានដាក់ពន្ធនាគារដោយកំបាំងមុខដោយសារបាញ់កម្មកររោងចក្របីនាក់* ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៣៖
http://www.scmp.com/news/asia/article/1268733/ex-cambodian-official-convicted-absentia។

[48] សេចក្តីសន្និដ្ឋានេះគឺស្របគ្នាជាមួយច្បាប់បារាំង ដែលទោះបីជាមិនអាចអនុវត្តបានៅក្នុងកម្ពុជាក៏ដោយ ក៏អាចផ្តល់ជាការណែនាំដោយមានសារៈប្រយោជន៍ក្នុងការបកស្រាយក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមានមូលដ្ឋានភាគច្រើនផ្អែកលើក្រមនីតិវិធីព្រហ្មទណ្ឌបារាំង)។ នៅប្រទេសបារាំង បន្ទាប់ពីការស្វែងរកត្រូវបានរាយការណ៍ថាគ្មានលទ្ធផលនោះ ជនសង្ស័យអាចត្រូវដាក់ឱ្យស្ថិតក្រោមការពិនិត្យដោយគ្មានវត្តមានគាត់។ *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ១៣៤៖ *"Si la personne ne peut être saisie, un procès-verbal de perquisition et de recherches infructueuses est adressé au magistrat qui a délivré le mandat. La personne est alors considérée comme mise en examen pour l'application de l'article 176."* *សូមមើល* មាត្រា ១៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង៖ *"Le juge d'instruction examine s'il existe contre la personne mise en examen des charges constitutives d'infraction, dont il détermine la qualification juridique".*

ដាក់ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*នោះទេ។ អាស្រ័យហេតុនេះ ស.ច.ស.អន្តរជាតិ នឹងស្វែងរកការណែនាំផ្នែកវិធានស្តីពីនីតិវិធីដែលបានបង្កើតឡើងនៅថ្នាក់អន្តរជាតិ។

<u>ភាពអាចទទួលយកកិច្ចដំណើរនីតិវិធី*ដោយកំបាំងមុខ*តាមច្បាប់សិទ្ធិមនុស្ស</u>

៤៧. យោងតាមមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ ១៩៦៦ ("ICCPR")[49] ជនជាប់ចោទមានសិទ្ធិមានវត្តមាននៅក្នុងការជំនុំជម្រះ ហើយមានសិទ្ធិការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់តាមការជ្រើសរើសរបស់ខ្លួន។ ទោះយ៉ាងណា នៅក្នុងកាលៈទេសៈពិសេស កិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ* អាចអនុវត្តបាន។ គណៈកម្មាធិការសិទ្ធិមនុស្ស បានសម្រេចថា សិទ្ធិមានវត្តមាននៅក្នុងការជំនុំជម្រះ៖

> "មិនអាចបកស្រាយក្នុងន័យ ដែលត្រូវតែធ្វើឱ្យកិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ* មិនអាចទទួលយកដោយមិនគិតដល់សំអាងហេតុដែលជនជាប់ចោទអវត្តមានឡើយ។ តាមពិត នៅក្នុងកាលៈទេសៈខ្លះ (ឧទាហរណ៍ នៅពេលដែលជនជាប់ចោទ ទោះបីជាត្រូវបានជូនដំណឹងជាមុនបានគ្រប់គ្រាន់អំពីកិច្ចដំណើរការនីតិវិធីយ៉ាងណាក៏ដោយ ប៉ុន្តែនៅតែបដិសេធមិនប្រើប្រាស់សិទ្ធិមានវត្តមាន) កិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ* អាចអនុវត្តបានដើម្បីជាប្រយោជន៍ដល់កិច្ចការរដ្ឋបាលតុលាការឱ្យបានត្រឹមត្រូវ"[50]។

៤៨. គណៈកម្មាធិការសិទ្ធិមនុស្ស ក៏បានបញ្ជាក់ថា "*នៅពេលដែលការជំនុំជម្រះដោយកំបាំងមុខត្រូវបានធ្វើឡើងក្នុងករណីពិសេស ដោយសារមានសំអាងហេតុប្រកបដោយយុត្តិកម្មនោះ អ្វីទាំងអស់ដែលចាំបាច់ជាងនេះគឺត្រូវគោរពដាច់ខាតនូវសិទ្ធិការពារក្តី*"[51]។

៤៩. កិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ*ស្របគ្នាជាមួយច្បាប់សិទ្ធិមនុស្ស ក៏ត្រូវបានបញ្ជាក់ផងដែរដោយតុលាការសិទ្ធិមនុស្សអឺរ៉ុប[52] ដែលបានសង្កត់ធ្ងន់ថា នៅពេលដែលជនណាម្នាក់ត្រូវ

---

[49] មាត្រា ១៤ និង ១៥ នៃកតិកាសញ្ញា ICCPR អាចអនុវត្តដោយផ្ទាល់នៅ អ.វ.ត.ក អនុលោមតាមមាត្រា ១២(២)នៃកិច្ចព្រមព្រៀង អ.វ.ត.ក។ ព្រះរាជាណាចក្រកម្ពុជា ក៏ជាភាគីនៅក្នុងកតិកាសញ្ញា ICCPR ដែរ ដែលកម្ពុជាបានផ្តល់សច្ចាប័ននៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩២។

[50] គណៈកម្មាធិការសិទ្ធិមនុស្ស រឿងក្តី *Daniel Monguya តទល់នឹង Zaire* អង្គការសហប្រជាជាតិ ឯកសារ CCPR/C/18/D/16/1977 ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៨៣ កថាខណ្ឌ ១៤.១។

[51] គណៈកម្មាធិការសិទ្ធិមនុស្ស មតិយោបល់រួម ១៣ មាត្រា ១៤ (សម័យប្រជុំលើកទី ២១ ឆ្នាំ ១៩៨៤) កថាខណ្ឌ ១១។

បានជំនុំជម្រះ*ដោយកំបាំងមុខ* គាត់គួរតែមានតំណាងមេធាវីគ្រប់គ្រាន់ និងទទួលបានការការពារប្រកបដោយប្រសិទ្ធភាព[53]។

<u>វិធានស្តីពីនីតិវិធីដែលបានផ្តើតនៅថ្នាក់អន្តរជាតិ</u>

*ក. តុលាការពិសេសសម្រាប់លីបង់*

៥០. មាត្រា ១៦ នៃលក្ខន្តិកៈរបស់តុលាការពិសេសសម្រាប់លីបង់("STL")ចែងថា ជនជាប់ចោទមានសិទ្ធិ *"ត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន និងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់តាមការជ្រើសរើសរបស់ខ្លួន[...]"*[54]។ លក្ខន្តិកៈរបស់តុលាការ STL ក៏អនុញ្ញាតឱ្យមានលទ្ធភាពនៃការរៀបចំការជំនុំជម្រះ*ដោយកំបាំងមុខ* តាមលក្ខខណ្ឌមួយចំនួនផងដែរ[55]។

៥១. មាត្រា២២(១)នៃលក្ខន្តិកៈរបស់តុលាការ STL ចែងថា កិច្ចដំណើរការនីតិវិធីជំនុំជម្រះដោយគ្មានវត្តមានរបស់ជនជាប់ចោទ អាចអនុវត្តបាននៅពេលដែលលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌខាងក្រោមត្រូវបានបំពេញ៖

"ក) ជនជាប់ចោទ បានបង្ហាញយ៉ាងច្បាស់ និងមានជាលាយលក្ខណ៍អក្សរថា គាត់បានលះបង់សិទ្ធិមានវត្តមានរបស់គាត់។

ខ) ជនជាប់ចោទមិនទាន់ត្រូវបានប្រគល់ជូនតុលាការ ពីអាជ្ញាធរពាក់ព័ន្ធរបស់រដ្ឋ ឬ

---

[52] *សូមមើល* តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Sejdovic តទល់នឹងអ៊ីតាលី* ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០០៦ កថាខណ្ឌ ៨៦។

[53] *សូមមើល* តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Lala តទល់នឹងហូល្លង់* ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៤ កថាខណ្ឌ ៣៣។ *សូមមើលផងដែរ* តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Krombach តទល់នឹងបារាំង* ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០១ កថាខណ្ឌ ៨៤។ តុលាការសិទ្ធិមនុស្សអឺរ៉ុប បានបន្ថែមថា *សារៈសំខាន់'ជាចាំបាច់'នៃការការពារជនជាប់ចោទ គួរតែសំខាន់ជាងសារៈសំខាន់ 'ជាគោលការណ៍'នៃការបង្ហាញខ្លួនរបស់ជនជាប់ចោទនៅក្នុងជំនុំជម្រះ*។ *សូមមើល* តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Sejdovic តទល់នឹងអ៊ីតាលី* ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០០៦ កថាខណ្ឌ ៦៩។

[54] លក្ខន្តិកៈរបស់តុលាការ STL មាត្រា ១៦។

[55] លក្ខន្តិកៈរបស់តុលាការ STL មាត្រា ២២។ វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ STL វិធាន ១០៥*ស្ទួន*។

គ) ជនជាប់ចោទ បានរត់គេច ឬមិនអាចរកឃើញ ហើយវិធានការសមហេតុផលទាំងអស់ត្រូវបានអនុវត្តរួចហើយដើម្បីធានាថា គាត់បានចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ និងដើម្បីជូនដំណឹងគាត់ អំពីបទចោទប្រកាន់ដែលបានបញ្ជាក់ដោយចៅក្រមបុរេជំនុំជម្រះ”[56]។

៥២. យោងតាមមាត្រា ២២(២)នៃលក្ខន្តិកៈរបស់តុលាការ STL នៅពេលដែលសវនាការត្រូវបានធ្វើឡើងដោយគ្មានវត្តមានរបស់ជនជាប់ចោទ តុលាការ STL ត្រូវតែធានាថា៖

“ក) ជនជាប់ចោទ ត្រូវបានជូនដំណឹង ឬត្រូវបានប្រគល់ជូននូវដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬការជូនដំណឹងអំពីដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានចេញផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ឬតាមរយៈការផ្សព្វផ្សាយទៅរដ្ឋដែលជនជាប់ចោទស្នាក់នៅ ឬមានសញ្ជាតិ។

ខ) ជនជាប់ចោទ បានតែងតាំងមេធាវីការពារក្តីតាមការជ្រើសរើសរបស់ខ្លួនដែលការចំណាយត្រូវរ៉ាប់រងដោយជនជាប់ចោទ ឬដោយតុលាការ ប្រសិនបើជនជាប់ចោទត្រូវបានបញ្ជាក់ថាជាជនក្រីក្រ។

គ) នៅពេលណាដែលជនជាប់ចោទ បដិសេធមិនតែងតាំង ឬខកខានមិនបានតែងតាំងមេធាវីការពារក្តី មេធាវីការពារក្តីបែបនោះត្រូវបានចាត់តាំងដោយការិយាល័យការពារក្តីរបស់តុលាការ ដើម្បីធានាថា ប្រយោជន៍ និងសិទ្ធិរបស់ជនជាប់ចោទមានតំណាងពេញលេញ”។

៥៣. វិធាន ១០៦(ក)នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ STL គឺដូចគ្នានឹងមាត្រា ២២(១) នៃលក្ខន្តិកៈរបស់តុលាការ STL។ វិធាន ១០៦(ខ) ចែងថា ក្នុងករណីដែលជនជាប់ចោទអវត្តមានដោយសារការខកខាន ឬការបដិសេធរបស់រដ្ឋមិនប្រគល់ជនជាប់ចោទនោះ មុនពេលសម្រេចអនុវត្តកិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ* អង្គជំនុំជម្រះសាលាដំបូងត្រូវតែ៖

---

[56] លក្ខន្តិកៈរបស់តុលាការ STL មាត្រា ២២។ វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ STL វិធាន ១០៦។

ក) ប្រឹក្សាជាមួយប្រធាន និងធានាថា វិធានការចាំបាច់ទាំងអស់ត្រូវបានអនុវត្តរួចហើយដើម្បីធានាថា ជនជាប់ចោទអាចចូលរួមកិច្ចដំណើរការនីតិវិធីនេះក្នុងរបៀបដែលសមស្របបំផុត ហើយ

ខ) ធានាថា លក្ខខណ្ឌតម្រូវនៃមាត្រា ២២(២)នៃលក្ខន្តិកៈត្រូវបានបំពេញ។

៥៤. នៅក្នុងការអនុវត្តតាមលក្ខខណ្ឌទាំងនេះ អង្គជំនុំជម្រះសាលាដំបូងនៃ តុលាការ STL បានចេញសេចក្តីសម្រេចចំនួនពីរដើម្បីរៀបចំសវនាការ *ដោយកំបាំងមុខ*។ អង្គជំនុះជម្រះសាលាដំបូង បានជឿជាក់ថា ជនជាប់ចោទ *"បានរត់គេច ឬមិនអាចរកឃើញ ហើយវិធានការសមហេតុផលទាំងអស់ត្រូវបានអនុវត្តរួចហើយដើម្បីធានាថា [ពួកគាត់]បានចូលបង្ហាញខ្លួន(...) និងដើម្បីជូនដំណឹង[ពួកគាត់]អំពីបទចោទប្រកាន់(...)"*[57]។ ដូច្នេះ នៅក្នុងរឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Ayyash និងអ្នកផ្សេងទៀត* អង្គជំនុំជម្រះបានសម្រេចថា ជនជាប់ចោទទាំងបួននាក់*"មិនមានបំណងចូលរួមសវនាការទេ"*[58] ហើយនៅក្នុងរឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Merhi* អង្គជំនុំជម្រះបានយល់ឃើញថា ជនជាប់ចោទ*"ប្រាកដជាបានជ្រើសរើសសម្រេចមិនចូលរួមសវនាការទេ ដូច្នេះគាត់បានលះបង់សិទ្ធិមានវត្តមានរបស់គាត់"*[59]។

*ខ. តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ("ICTY") និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉្វាន់ដា ("ICTR")*

---

[57] *សូមមើល*តុលាការ STL-11-01/I/TC *រដ្ឋអាជ្ញាតទល់នឹង Ayyash និងអ្នកផ្សេងទៀត* សេចក្តីសម្រេចរៀបចំសវនាការ*ដោយកំបាំងមុខ* ថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១០៧-១១០។ *សូមមើលផងដែរ* STL-13-04/I/TC *រដ្ឋអាជ្ញាតទល់នឹង* Merhi *សេចក្តីសម្រេចរៀបចំសវនាការដោយកំបាំងមុខ* ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៣ កថាខណ្ឌ ៤ និង ១១១។ *សូមមើលផងដែរ* STL-11-O1/PT/AC/ARI26.1 *រដ្ឋអាជ្ញាតទល់នឹង Ayyash និងអ្នកផ្សេងទៀត សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្តីប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការពិចារណាឡើងវិញលើសវនាការដោយកំបាំងមុខ* ថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១២ កថាខណ្ឌ ៤៦ និង ៥១។

[58] តុលាការ STL-11-01/I/TC *រដ្ឋអាជ្ញាតទល់នឹង Ayyash និងអ្នកផ្សេងទៀត សេចក្តីសម្រេចរៀបចំសវនាការដោយកំបាំងមុខ* ថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១១១។

[59] តុលាការ STL-13-04/I/TC *រដ្ឋអាជ្ញាតទល់នឹង Merhi សេចក្តីសម្រេចរៀបចំសវនាការដោយកំបាំងមុខ* ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៣ កថាខណ្ឌ ១០៩។ *សូមមើលផងដែរ* STL-11-O1/PT/AC/AR126.1 *រដ្ឋអាជ្ញាតទល់នឹង Ayyash និងអ្នកផ្សេងទៀត សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្តីប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការពិចារណាឡើងវិញលើសវនាការដោយកំបាំងមុខ* ថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១២ កថាខណ្ឌ ៣១។

៥៥. វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY និង ICTR អនុញ្ញាតឲ្យមានកិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ* ក្នុងករណីដែលមានការខកខានមិនបានអនុវត្តដីកានាំខ្លួន[60]។ វិធានការបែបនេះត្រូវយកមកប្រើប្រាស់ប្រសិនបើ "*វិធានការសមហេតុផលទាំងអស់*"ត្រូវបានអនុវត្តរួចហើយដើម្បីធានាថា ជនជាប់ចោទត្រូវបាននាំខ្លួន និងដើម្បីស្វែងរកកន្លែងលាក់ខ្លួនរបស់គាត់[61]។ អង្គជំនុំជម្រះសាលាដំបូងនៅតុលាការ ICTY បានបង្ហាញពីសារៈសំខាន់នៃយន្តការបែបនេះ ដោយសង្កត់ធ្ងន់ថា "*យុត្តិធម៌ឧក្រិដ្ឋកម្មអន្តរជាតិ ដែលមិនអាចសម្រេចតាមការខកខានរបស់បុគ្គល ឬរដ្ឋនានានោះទេ គឺត្រូវតែបន្តបេសកកម្មរបស់ខ្លួនក្នុងការលាតត្រដាងការពិតអំពីអំពើដែលបានប្រព្រឹត្ត និងទុក្ខលំបាកដែលបានទទួលរង ព្រមទាំងរកអត្តសញ្ញាណ និងនាំខ្លួនជនដែលត្រូវបានចោទថាជាអ្នកទទួលខុសត្រូវ*"[62]។

*គ. តុលាការព្រហ្មទណ្ឌអន្តរជាតិ("ICC")*

៥៦. មាត្រា ៦១(២)នៃលក្ខន្តិកៈក្រុងរ៉ូមរបស់តុលាការ ICC វិធាន ១២៥ នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICC អនុញ្ញាតឲ្យមានការបញ្ជាក់អំពីសវនាការស្តីពីបទចោទប្រកាន់*ដោយកំបាំងមុខ* ប្រសិនបើជនជាប់ចោទ"*បានលះបង់សិទ្ធិមានវត្តមានរបស់គាត់*"ជាលាយលក្ខណ៍អក្សរ ឬ"*បានគេចខ្លួន ឬមិនអាចរកឃើញ ហើយវិធានការសមហេតុផលទាំងអស់ត្រូវបានអនុវត្តរួចហើយដើម្បីធានាថាគាត់បានចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ និងដើម្បី*

---

[60]នេះរួមបញ្ចូលទាំងការបញ្ជាក់ឡើងវិញអំពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងលទ្ធភាពដែលរដ្ឋអាជ្ញាអាចផ្តល់ភស្តុតាងគាំទ្រ ឬភស្តុតាងបន្ថែម។ សវនាការបែបនេះមានបំណងសម្រេចលើភាពគ្រប់គ្រាន់នៃភស្តុតាងបឋមដែលដាក់ដោយរដ្ឋអាជ្ញា និងដើម្បីសម្រេចថាតើមានមូលដ្ឋានសមហេតុផលដែលជឿថា ជនជាប់ចោទ បានប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយ ឬឧក្រិដ្ឋកម្មទាំងអស់ដែលបានចោទ។ *សូមមើល*ឯកសារអង្គការសហប្រជាជាតិ A/51/292-S/1996/665 របាយការណ៍មហាសន្និបាត លើកទី ២១ របស់តុលាការ ICTY ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ១៩៩៦ កថាខណ្ឌ ៥០-៦១។

[61] វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY និង ICTR វិធាន ៦១។

[62] IT-95-5-R61 និង IT-95-18-R61 រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Radovan Karadzic និង Ratko Mladic* ការពិនិត្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ អនុលោមតាមវិធាន ៦១ នៃវិធានស្តីពីនីតិវិធី និងភស្តុតាង ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៩៦ កថាខណ្ឌ ៣។

*ជូនដំណឹងគាត់អំពីបទចោទប្រកាន់ ហើយសវនាការដើម្បីបញ្ជាក់អំពីការចោទប្រកាន់ទាំងនោះនឹងត្រូវរៀបចំធ្វើឡើង*"[63]។

<u>សេចក្តីសន្និដ្ឋាន</u>

៥៧. ដោយផ្អែកលើការពិនិត្យមើលច្បាប់កម្ពុជា និងវិធានស្តីពីនីតិវិធី និងភស្តុតាងដែលបានបង្កើតឡើងនៅថ្នាក់អន្តរជាតិ និងដោយបានពិចារណាលើភាពខុសគ្នានៅក្នុងនីតិវិធីដែលអាចអនុវត្តបាននៅ អ.វ.ត.ក និងនៅតុលាការអន្តរជាតិក្នុងករណីដែលវិធានស្តីពីនីតិវិធីទាំងនេះបានបង្កើតឡើងនោះ ស.ច.ស.អន្តរជាតិ សន្និដ្ឋានថា៖

ក) វិធានផ្ទៃក្នុង ខណៈដែលចែងអំពីដំណើរការដាក់ឱ្យស្ថិតក្រោមការពិនិត្យដោយមានវត្តមានរបស់ជនសង្ស័យយ៉ាងណាក៏ដោយ ក៏មិនតម្រូវថា វត្តមានរបស់ជនសង្ស័យនៅក្នុងការបង្ហាញខ្លួនលើកដំបូង គឺជាបុរេលក្ខខណ្ឌមួយដែលចាំបាច់ដើម្បីបន្តកិច្ចដំណើរការនីតិវិធីដាក់ឱ្យស្ថិតក្រោមការពិនិត្យទេ។ វិធានផ្ទៃក្នុង មិនមានចែងអំពីនីតិវិធីដែលត្រូវអនុវត្តនៅពេលដែលដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យ ដែលជនសង្ស័យនោះខកខានមិនបានចូលរួមក្នុងការបង្ហាញខ្លួនលើកដំបូង។

ខ) កិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ* ត្រូវបានអនុញ្ញាតតាមច្បាប់កម្ពុជា។

គ) កិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ* អាចទទួលយកតាមច្បាប់សិទ្ធិមនុស្សនៅក្នុងកាលៈទេសៈមួយចំនួន ដូចជា ជនដែលអាចស្ថិតនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌបានបដិសេធមិនចូលបង្ហាញខ្លួន នៅចំពោះមុខតុលាការមានសមត្ថកិច្ច។

ឃ) វិធានស្តីពីនីតិវិធីដែលបានបង្កើតឡើងនៅថ្នាក់អន្តរជាតិ អនុញ្ញាតឱ្យមានកិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ*នៅពេលដែលជនណាម្នាក់ បានបង្ហាញ

---

[63] លក្ខន្តិកៈក្រុងរ៉ូម មាត្រា ៦៣(២)។ វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICC វិធាន ១២៤(១)។ *សូមមើល* ICC-02/05-03/09 រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Abdallah Banda Abaer Nourain និង Saleh Mohammed Jerbo Jamus* សេចក្តីសម្រេចលើបញ្ហាទាក់ទងនឹងសវនាការស្តីពីការបញ្ជាក់អំពីបទចោទប្រកាន់ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១០។

យ៉ាងច្បាស់ និងមានជាលាយលក្ខណ៍អក្សរថាបានលះបង់សិទ្ធិមានវត្តមានរបស់គាត់ ឬនៅពេលដែលវិធានការសមហេតុផលទាំងអស់ត្រូវបានអនុវត្តរួចហើយដើម្បីធានាថា គាត់បានចូលបង្ហាញខ្លួននៅចំពោះមុខតុលាការមានសមត្ថកិច្ច និងដើម្បីជូនដំណឹងគាត់ អំពីបទចោទប្រកាន់ ប៉ុន្តែ កិច្ចខិតខំប្រឹងប្រែងទាំងនោះមិនបានទទួលជោគជ័យ។

ង) នៅពេលដែលរៀបចំកិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ* តុលាការចាំបាច់ត្រូវតែធានាថា ជនជាប់ចោទ ឬជនត្រូវចោទដែលអវត្តមាន មានតំណាងគ្រប់គ្រាន់ និងប្រកបដោយប្រសិទ្ធភាព។

៥៨. អាស្រ័យហេតុ ស.ច.ស.អន្តរជាតិ ជឿជាក់ថា ច្បាប់ដែលអាចអនុវត្តបាននៅ អ.វ.ត.ក អនុញ្ញាតឱ្យដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*នៅពេលដែលជនសង្ស័យបានបដិសេធមិនចូលបង្ហាញខ្លួនលើកដំបូងអនុលោមវិធានផ្ទៃក្នុង ៥៧ និងនៅពេលដែលកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់មកទៀតដើម្បីធានាថាជនសង្ស័យមានវត្តមាន មិនបានទទួលលទ្ធផល។

**ពិភាក្សា**

**ការបំពេញតាមលក្ខខណ្ឌតម្រូវផ្លូវច្បាប់ដើម្បីដាក់អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ***

<u>អ៊ឹម ចែម បានដឹងឮពីកាលបរិច្ឆេទ និងពេលវេលានៃការបង្ហាញខ្លួនលើកដំបូងរបស់គាត់</u>

៥៩. ស.ច.ស.អន្តរជាតិ បានសម្រេចថា មានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា អ៊ឹម ចែម អាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មមួយចំនួនដែលបានចោទនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[64]។ ហេតុនេះ នៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៥ ស.ច.ស.អន្តរជាតិ បានចេញដីកាកោះដែលបានប្រគល់ជូនអ៊ឹម ចែម ដោយផ្ទាល់នៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៥។

[64] *សូមមើល* ការជូនដំណឹងអំពីបទចោទប្រកាន់ ភ្ជាប់ជាមួយដីកាសម្រេចនេះ។

៦០. សហមេធាវីរបស់ អ៊ឹម ចែម ត្រូវបានជូនដំណឹងអំពីការបង្ហាញខ្លួនលើកដំបូងដែលបានគ្រោងទុក ហើយតាមរយៈការប្រាស្រ័យទាក់ទងរវាងសហមេធាវី ជាមួយ ស.ច.ស.អន្តរជាតិ នៅថ្ងៃទី ៨ និងថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៤ គឺច្បាស់ថា សហមេធាវី បានទាក់ទងអ៊ឹម ចែម និងបានទទួលការណែនាំពីគាត់នៅក្នុងរយៈកាលនេះ។ ឧទាហរណ៍ នៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៤ សហមេធាវីអន្តរជាតិរបស់ អ៊ឹម ចែម បានជូនដំណឹង ស.ច.ស.អន្តរជាតិ ថា កូនក្តីរបស់គាត់មិនមានចេតនាចូលបង្ហាញខ្លួន តាមដីកាកោះដែលបានចុះហត្ថលេខាតែ ស.ច.ស.អន្តរជាតិ តែម្នាក់ឯងនោះទេ[65]។

៦១. ការដឹងឮរបស់អ៊ឹម ចែម អំពីការបង្ហាញខ្លួនលើកដំបូងដែលគ្រោងធ្វើឡើងនៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤ និងចេតនារបស់គាត់មិនព្រមគោរពតាមដីកាកោះនោះ ក៏មានភស្តុតាងបញ្ជាក់ផងដែរតាមរយៈអត្ថបទសារព័ត៌មានរបស់ប្រព័ន្ធផ្សព្វផ្សាយ។ នៅថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១៤ សារព័ត៌មាន*ភ្នំពេញប៉ុស្តិ៍* តាមគេហទំព័រអ៊ីនធើណិត បានចេញផ្សាយអត្ថបទមួយដែលក្នុងនោះ សារព័ត៌មាននេះបានរាយការណ៍អំពីសេចក្តីដកស្រង់ពីបទសម្ភាសន៍មួយជាមួយ អ៊ឹម ចែម។ *ភ្នំពេញប៉ុស្តិ៍* បានរាយការណ៍ថា អ៊ឹម ចែម បានបញ្ជាក់ថា គាត់មិនមានបំណងចូលបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក ទេ[66]។ នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ *សំឡេងសហរដ្ឋអាមេរិកខេមរៈភាសា* បានរាយការណ៍ថា នាពេលថ្មីៗនេះ គាត់បានបដិសេធមិនចុះហត្ថលេខា ឬក៏ទទួលយក *"ដីកាចោទប្រកាន់"* ដែល *"មន្ត្រីមកពីសាលាក្តី"* បានប្រគល់ជូនគាត់[67]។

៦២. ស.ច.ស.អន្តរជាតិ ជឿជាក់ថា កាលទេសៈទាំងនេះ បង្ហាញយ៉ាងច្បាស់ថា អ៊ឹម ចែម ត្រូវបានជូនដំណឹងអំពីការបង្ហាញខ្លួនលើកដំបូងដែលគ្រោងធ្វើឡើងនៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤ ប៉ុន្តែមានចេតនាមិនចូលបង្ហាញខ្លួន ដូច្នេះបានលះបង់សិទ្ធិរបស់ខ្លួនក្នុងការមានវត្តមាននៅក្នុង

---

[65] ការប្រាស្រ័យទាក់ទងរវាងសហមេធាវីរបស់អ៊ឹម ចែម ជាមួយ ស.ច.ស.អន្តរជាតិ ទាក់ទងនឹងលទ្ធភាពដែលអាចដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ គឺមានបញ្ជាក់លម្អិតនៅក្នុងផ្នែកស្តីពីប្រវត្តិនីតិវិធី នៃដីកាសម្រេចនេះ។

[66] *សូមមើល* សារព័ត៌មាន ភ្នំពេញ ប៉ុស្តិ៍ *បន្ទាប់ពីចេញសាលក្រម ជនសង្ស័យខ្មែរក្រហម នៅតែមានៈ* ថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១៤៖ http://www.phnompenhpost.com/post-weekend/after-verdict-kr-suspect-remains-defiant។

[67] *សូមមើល* សំឡេងសហរដ្ឋអាមេរិក *ជនសង្ស័យខ្មែរក្រហម បដិសេធមិនទៅតាមសាលាក្តី* ថ្ងៃទី១៨ ខែសីហា ឆ្នាំ ២០១៤៖ http://www.voacambodia.com/content/khmer-rouge-suspect-refuses-to-go-along-with-tribunal/2417173.html។

ការបង្ហាញខ្លួនលើកដំបូង។ ស.ច.ស.អន្តរជាតិ ក៏ជឿជាក់ថា អ៊ឹម ចែម បានបង្ហាញថាគាត់មិនមានចេតនាចូលបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក នៅថ្ងៃណាមួយនោះទេ។

<u>វិធានការដើម្បីធានាថា អ៊ឹម ចែម បានចូលបង្ហាញខ្លួន មិនបានទទួលជោគជ័យ</u>

៦៣. នៅថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៤ ដោយអនុលោមតាមមាត្រា ២៥(គ)នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងវិធានផ្ទៃក្នុង ១៥ និងបន្ទាប់ពីអ៊ឹម ចែម មានចេតនាមិនបានចូលបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក នោះ ស.ច.ស.អន្តរជាតិ បានចេញដីកានាំខ្លួន ហើយបានស្នើនគរបាលយុត្តិធម៌ ឱ្យនាំខ្លួនអ៊ឹម ចែម មកនៅចំពោះមុខគាត់សម្រាប់ការបង្ហាញខ្លួនលើកដំបូង។

៦៤. រវាងថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៤ ដល់កាលបរិច្ឆេទនៃដីកាសម្រេចនេះ ស.ច.ស.អន្តរជាតិ បានទាក់ទងនគរបាលយុត្តិធម៌ ដោយស្នើសុំព័ត៌មានបច្ចុប្បន្នភាពអំពីការអនុវត្តដីកានាំខ្លួន ហើយរវាងថ្ងៃទី ១១ ដល់ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៤ បានអនុវត្តកម្មវិធីផ្សព្វផ្សាយចំនួនប្រាំបួនដាច់ដោយឡែកពីគ្នានៅក្នុងតំបន់នានាតាមការណែនាំរបស់អាជ្ញាធរកម្ពុជា។

៦៥. នៅក្នុងកិច្ចប្រជុំថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៤ តំណាងម្នាក់របស់នគរបាលយុត្តិធម៌ បានជូនដំណឹង ស.ច.ស.អន្តរជាតិថា គ្មានការវិវឌ្ឍនៅក្នុងការអនុវត្តដីកានាំខ្លួនទេ ហើយគាត់មិនអាចផ្តល់ការប៉ាន់ស្មានគួរឱ្យទុកចិត្តបាន ថាតើដីកានាំខ្លួននឹងត្រូវអនុវត្តនៅពេលណានោះទេ ហើយសេចក្តីសម្រេចចុងក្រោយថាតើដីកានាំខ្លួននឹងត្រូវអនុវត្តនៅពេលណានោះ គឺស្ថិតនៅលើគណៈកម្មការសន្តិសុខប្រចាំ អ.វ.ត.ក។ បន្ទាប់ពីកិច្ចប្រជុំនេះ ស.ច.ស.អន្តរជាតិ បានផ្ញើលិខិតមួយច្បាប់ជូនទៅប្រធានគណៈកម្មកាសន្តិសុខប្រចាំ អ.វ.ត.ក ដោយជូនដំណឹងគាត់ថា ប្រសិនបើ អ៊ឹម ចែម មិនចូលបង្ហាញខ្លួន ឬមិនត្រូវបាននាំមកបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក នៅត្រឹមថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥នោះទេ ស.ច.ស.អន្តរជាតិ នឹងបន្តកិច្ចដំណើរការនីតិវិធីដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*[68]។

៦៦. ស.ច.ស.អន្តរជាតិ មិនបានទទួលការឆ្លើយតបទៅនឹងលិខិតដែលបានផ្ញើជូនប្រធានគណៈកម្មការសន្តិសុខប្រចាំ អ.វ.ត.ក ទេ។ កាលបរិច្ឆេទថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥ ដែលបាន

[68] ការប្រាស្រ័យទាក់ទងទាំងនេះត្រូវបានសង្ខេបនៅក្នុងផ្នែកប្រវត្តិនីតិវិធីនៃដីកាសម្រេចនេះ។

កំណត់នោះ ឥឡូវនេះបានកន្លងផុតហើយ ដោយអ៊ឹម ចែម មិនបានចូលបង្ហាញខ្លួននៅ អ.វ.ត.ក ហើយ នគរបាលយុត្តិធម៌ ក៏មិនបានអនុវត្តដីកានាំខ្លួនដែរ។

៦៧. ស.ច.ស.អន្តរជាតិ ជឿជាក់ថា អ៊ឹម ចែម មិនលាក់ខ្លួនទេ[69] នគរបាលយុត្តិធម៌ដឹងពីទីកន្លែងដែល អ៊ឹម ចែម ស្នាក់នៅ នគរបាលយុត្តិធម៌ មានមធ្យោបាយជាក់ស្តែងដើម្បីអនុវត្តដីកានាំខ្លួន ហើយនគរបាលយុត្តិធម៌ មិនបានបំពេញការទទួលខុសត្រូវដែលបានកំណត់ដោយកិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង។ ដូច្នេះ ស.ច.ស.អន្តរជាតិ ជឿជាក់ថា វិធានការសមហេតុផលទាំងអស់ត្រូវបានអនុវត្តរួចហើយដើម្បីធានាថា អ៊ឹម ចែម បានចូលបង្ហាញខ្លួននៅ អ.វ.ត.ក សម្រាប់ការបង្ហាញខ្លួនលើកដំបូងដោយអនុលោមតាមវិធានផ្ទៃក្នុង ៥៧។

៦៨. ដូច្នេះ ស.ច.ស.អន្តរជាតិ យល់ឃើញថា លក្ខខណ្ឌតម្រូវផ្លូវច្បាប់ទាំងអស់ដើម្បីដាក់ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ត្រូវបានបំពេញរួចហើយ។

### ការពិចារណាផ្សេងទៀតដែលតម្រូវថា អ៊ឹម ចែម ត្រូវដាក់ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*

៦៩. ជនសង្ស័យ មិនមែនជាភាគីនៅក្នុងកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០៤ ទេ។ ដូច្នេះ ជនសង្ស័យ មិនមានសិទ្ធិចូលពិនិត្យមើលសំណុំរឿង ចូលរួមការស៊ើបអង្កេតរបស់តុលាការ[70] តទល់ជាមួយសាក្សី[71] ឬក៏ស្នើឱ្យ ស.ច.ស ដាក់ពាក្យសុំមោឃភាពកិច្ចស៊ើបសួរទៅ អ.ប.ជ

---

[69] អ៊ឹម ចែម ត្រូវបានសម្ភាសដោយ *សំឡេងសហរដ្ឋអាមេរិក* នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ *សូមមើល* សំឡេងសហរដ្ឋអាមេរិក *ជនសង្ស័យខ្មែរក្រហម បដិសេធមិនទៅតាមសាលាក្តី* ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤៖, http://www.voacambodia.com/content/khmer-rouge-suspect-refuses-to-go-along-with-tribunal/2417173.html ។ អ៊ឹម ចែម ក៏បានចូលរួម និងនិយាយនៅក្នុងកម្មវិធីផ្សព្វផ្សាយដែលរៀបចំឡើងដោយ ស.ច.ស.អន្តរជាតិ នៅថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៤ នៅអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ប្រទេសកម្ពុជា។

[70] *សូមមើល* វិធានផ្ទៃក្នុង ៥៥(៥) និង ៥៥(១០) និងសន្ទានុក្រមនៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* សំណុំរឿង ០០៤ ឯកសារ D121/4 *សេចក្តីសម្រេចលើណើរបស់ក្រុមមេធាវីការពារក្តី[កោសលុប]សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត* ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ៣៦-៣៩ និង ៦២។

[71] *សូមមើល* វិធានផ្ទៃក្នុង ៦០(២)។

ទេ[72]។ ជនសង្ស័យអាចប្រើប្រាស់សិទ្ធិទាំងនេះបាន លុះត្រាតែជនសង្ស័យត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យ។ ស.ច.ស.អន្តរជាតិ អាចចេញការជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរបានតែពេលណាដែលភាគីទាំងអស់ រួមបញ្ចូលទាំងជនត្រូវចោទ មានឱកាសចូលរួមដំណើរការស៊ើបអង្កេត និងនៅពេលណាដែល ស.ច.ស ពិចារណាថា កិច្ចស៊ើបសួរបានបញ្ចប់[73]។ ការជូនដំណឹងបែបនេះនាំឱ្យមានវិធានការនីតិវិធីបន្ថែមទៀត ដែលចុងក្រោយបំផុតនឹងនាំឱ្យមានការចេញដីកាដំណោះស្រាយ ដែលអាចជាដីកាលើកលែងការចោទប្រកាន់ ឬក៏ជាដីកាចោទប្រកាន់ ហើយបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ[74]។

៧០. ការខកខានដោយចេតនារបស់អ៊ឹម ចែម ដែលមិនបានចូលបង្ហាញខ្លួនលើកដំបូង ឬក៏ការខកខានរបស់នគរបាលយុត្តិធម៌ដែលមិនបានអនុវត្តដីកានាំខ្លួនឱ្យបានឆាប់រហ័ស ដោយឥតពន្យារពេលយូរហួសដើម្បីនាំគាត់មកបង្ហាញខ្លួននៅចំពោះមុខតុលាការនោះ មិនអាចបណ្តោយឱ្យដំណើរការស៊ើបអង្កេតរបស់តុលាការជាប់គាំងទេ បើមិនអញ្ចឹងទេវានឹងរារាំង ស.ច.ស មិនឱ្យអនុវត្តការទទួលខុសត្រូវរបស់ខ្លួនក្នុងការបំពេញកិច្ចស៊ើបសួរនៅក្នុងសំណុំរឿងឱ្យបានចប់សព្វគ្រប់នោះទេ។ ទង្វើបែបនេះនឹងធ្វើឱ្យ អ៊ឹម ចែម និងនគរបាលយុត្តិធម៌ មានសមត្ថភាពអាចកំណត់ថាតើកិច្ចស៊ើបសួររបស់តុលាការនៅ អ.វ.ត.ក អាចដំណើរការបានឬអត់ ហើយទង្វើបែបនេះនឹងរារាំងគោលបំណងនៃច្បាប់ ដែលត្រូវវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តរវាងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩។

៧១. ការពន្យារពេលបន្ថែមទៀតក៏នឹងធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់អ៊ឹម ចែម ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ រួមបញ្ចូលទាំងសិទ្ធិមានពេលវេលា និងសម្ភារៈរូបវ័ន្តគ្រប់គ្រាន់ក្នុងការចូលរួមកិច្ចស៊ើបសួរ និងរៀបចំការការពារខ្លួន សិទ្ធិស្នើសុំឱ្យមានការចូលរួមពីសាក្សី

---

[72] *សូមមើល* វិធានផ្ទៃក្នុង ៧៦(២)។ *សូមមើលផងដែរ* សំណុំរឿង ០០៤ ឯកសារ D207/1 *ដីកាសម្រេចលើសំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម ស្នើសុំឱ្យបញ្ជូនសំណើសុំមោឃភាពដីកាកោះហៅអ្នកស្រី និងសហមេធាវីការពារក្តីគាត់ទៅអង្គបុរេជំនុំជម្រះ* ថ្ងៃទី១៨ ខែសីហា ឆ្នាំ ២០១៤។ សំណុំរឿង ០០៤ ឯកសារ *ដីកាសម្រេចលើញត្តិ[កោសលុប] សុំមោឃភាពកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៧៦នៃវិធានផ្ទៃក្នុង* ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៤ កថាខណ្ឌ ៣៣។

[73] *សូមមើល* វិធានផ្ទៃក្នុង ៦៦។

[74] *សូមមើល* វិធានផ្ទៃក្នុង ៦៧។

តាមរយៈការដាក់សំណើសុំបំពេញកិច្ចស៊ើបសួរទៅ ស.ច.ស និងសិទ្ធិទទួលបានថិរវេលាសមហេតុផលសម្រាប់កិច្ចដំណើរការនីតិវិធីប្រឆាំងគាត់[75]។

៧២. បន្ថែមពីលើនេះទៀត ការពន្យារពេលបន្ថែមទៀតរបស់នគរបាលយុត្តិធម៌ក្នុងការនាំខ្លួន អ៊ឹម ចែម មកចំពោះមុខ អ.វ.ត.ក ឬក៏ការខកខានមិននាំខ្លួនគាត់ នឹងធ្វើឱ្យប៉ះពាល់ដល់សិទ្ធិជនរងគ្រោះ និងប្រជាជនកម្ពុជា ហើយអាចនាំឱ្យមិនមានការគោរពដល់ អ.វ.ត.ក ដែលជាផ្នែកមួយដ៏ពិសេស និងសំខាន់នៅក្នុងប្រព័ន្ធតុលាការកម្ពុជា។

## សេចក្តីសន្និដ្ឋាន

៧៣. ដោយពិចារណាថា មានភាពមិនច្បាស់លាស់ទាល់តែសោះថាតើដីកានាំខ្លួននឹងត្រូវអនុវត្តនៅពេលណា ហើយត្រូវអនុវត្តឬអត់នោះ ស.ច.ស.អន្តរជាតិ យល់ឃើញថា ការដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* គឺជាវិធីតែមួយគត់ដើម្បីធានាថា កិច្ចដំណើរការនីតិវិធីអនុវត្តបានដោយយុត្តិធម៌ និងបានឆាប់រហ័ស។ ដោយបានចេញដីកាសម្រេចនេះ ឋានៈរបស់ អ៊ឹម ចែម ត្រូវតែផ្លាស់ប្តូរពី"ជនសង្ស័យ"ទៅជា"ជនត្រូវចោទ" ដូច្នេះ អ៊ឹម ចែម នឹងអាចប្រើប្រាស់សិទ្ធិទាំងអស់ ដែលជនត្រូវចោទមានសិទ្ធិទទួលបានតាមវិធានផ្ទៃក្នុង។ ការផ្លាស់ប្តូរឋានៈរបស់ អ៊ឹម ចែម ធ្វើឱ្យអស់សុពលភាពចំពោះសំណើសុំចូលពិនិត្យមើលសំណុំរឿង និងទឡ្ហីករណ៍បន្ថែមលើសំណើសុំចូលពិនិត្យមើលសំណុំរឿង ពីព្រោះថា ការចូលពិនិត្យមើលសំណុំរឿង ០០៤ នឹងអនុញ្ញាតឱ្យភ្លាមនៅពេលដែលចេញដីកាសម្រេចនេះ។

៧៤. ស.ច.ស.អន្តរជាតិ កត់សម្គាល់ថា អ៊ឹម ចែម មានសហមេធាវីតាមការជ្រើសរើសរបស់ខ្លួនជាតំណាងរួចហើយ[76]។

---

[75] អនុលោមតាមវិធានផ្ទៃក្នុង ៥៥ មានតែជនត្រូវចោទ និងភាគីផ្សេងទៀតដែលអាចចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេតរបស់តុលាការ។ ជនសង្ស័យ ក្នុងឋានៈមិនមែនជាភាគី មិនមានសិទ្ធិទាំងនេះ។ *សូមមើលផងដែរ* សំណុំរឿង០០៤ ឯកសារ D121/4 *សេចក្តីសម្រេចលើសំណើរបស់ក្រុមមេធាវីការពារក្តី[កោសលុប] សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត* ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ៣៦-៣៩ និងកថាខណ្ឌ ៦២។

[76] សំណុំរឿង ០០៤ ឯកសារ D122/11 *ដីកាសម្រេចទទួលស្គាល់មេធាវីតំណាងអ៊ឹម ចែម* ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៤ ដាក់នៅថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៤។ សំណុំរឿង ០០៤ ឯកសារ D122/13/1 *ដីកាសម្រេចទទួលស្គាល់សហមេធាវីអន្តរជាតិតំណាង អ៊ឹម ចែម* ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៤។

៧៥. ដើមហេតុ និងលក្ខណៈនៃបទចោទប្រកាន់ប្រឆាំងអ៊ឹម ចែម ព្រមទាំងព័ត៌មានលម្អិតផ្ទាល់ខ្លួនរបស់គាត់ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត គឺមានបញ្ជាក់នៅក្នុងការជូនដំណឹងអំពីបទចោទប្រកាន់ដែលភ្ជាប់ជាមួយដីកាសម្រេចនេះ។

**តាមសំអាងហេតុខាងលើ ខ្ញុំ** MARK B. HARMON ៖

៧៦. **សម្រេចដាក់** អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ដូចបានបញ្ជាក់នៅក្នុងការជូនដំណឹងអំពីបទចោទប្រកាន់ដែលភ្ជាប់មកជាមួយដីកាសម្រេចនេះ។

៧៧. **បង្គាប់ឱ្យ**ក្រឡាបញ្ជី ចាត់វិធានការចាំបាច់ដើម្បីធានាថា សហមេធាវីរបស់អ៊ឹម ចែម ទទួលបានការអនុញ្ញាតចូលពិនិត្យមើលសំណុំរឿង ០០៤ ឱ្យបានឆាប់តាមការជាក់ស្តែង។

៧៨. **ប្រកាសថា** សំណើសុំចូលពិនិត្យមើលសំណុំរឿង និងទឡ្ហីករណ៍បន្ថែមលើសំណើសុំចូលពិនិត្យមើលសំណុំរឿងលែងមានសុពលភាពទៀតហើយ។

ភ្នំពេញ ថ្ងៃទី៣ ខែ មីនា ឆ្នាំ ២០១៥

**ចៅក្រម Mark B. Harmon**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**International Co- Investigating Judge**

**Co-juge d'instruction international**